# អត្ថបទគោល

របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
សម្រាប់អធិប្បាយ ផ្តល់ការបំភ្លឺ
ស្តីពី

# ការចារបោះបង្គោលខណ្ឌសីមាព្រំដែនគោក និង ការកំណត់ព្រំដែនសមុទ្រ រវាង ព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋសង្គមនិយមវៀតណាម

សម័យប្រជុំពេញអង្គរដ្ឋសភា ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១២



សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន ៖**
«គោលការណ៍សំខាន់នៅទីនេះ គឺធានាឱ្យបានដាច់ខាតថា
កម្ពុជានឹងមិនខាត ឬ បាត់បង់ដីឡើយ សូម្បីតែ ១ ម៉ែត្រក្រឡាក៏ដោយ»

# មាតិកា


អត្ថបទគោលរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់អធិប្បាយ ផ្តល់ការបំភ្លឺ ស្តីពី "**ការខារបោះបង្គោលខណ្ឌសីមាព្រំដែនគោក និងការកំណត់ព្រំដែនសមុទ្ររវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម**" ក្នុងកិច្ចប្រជុំពេញអង្គនៃរដ្ឋសភា ថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០១២ ........................................................ទំព័រទី១-៣៨

ឧបសម្ព័ន្ធទី ១ ........................................................................ទំព័រទី ៣៩
ឧបសម្ព័ន្ធទី ២ ........................................................................ទំព័រទី ៤៥
ឧបសម្ព័ន្ធទី ៣ ........................................................................ទំព័រទី ៤៧
ឧបសម្ព័ន្ធទី ៤ ........................................................................ទំព័រទី ៤៨
ឧបសម្ព័ន្ធទី ៥ ........................................................................ទំព័រទី ៤៩
ឧបសម្ព័ន្ធទី ៦ ........................................................................ទំព័រទី ៥០
ឧបសម្ព័ន្ធទី ៧ ........................................................................ទំព័រទី ៥២
ឧបសម្ព័ន្ធទី ៨ ........................................................................ទំព័រទី ៥៥
ឧបសម្ព័ន្ធទី ៩ ........................................................................ទំព័រទី ៥៦
ឧបសម្ព័ន្ធទី ១០ ......................................................................ទំព័រទី ៦១
ឧបសម្ព័ន្ធទី ១១ ......................................................................ទំព័រទី ៦៤
ឧបសម្ព័ន្ធទី ១២ ......................................................................ទំព័រទី ៦៧
ឧបសម្ព័ន្ធទី ១៣ ......................................................................ទំព័រទី ៦៨
ឧបសម្ព័ន្ធទី ១៤ ......................................................................ទំព័រទី ៧២
ឧបសម្ព័ន្ធទី ១៥ ......................................................................ទំព័រទី ៧៦

# រាជរដ្ឋាភិបាលកម្ពុជា

## អត្ថបទគោល

### របស់ សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
### នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
### សម្រាប់អធិប្បាយ ផ្ដល់ការបំភ្លឺ
### ស្ដីពី

# ការងារបោះបង្គោលខណ្ឌសីមាព្រំដែនគោក និង ការកំណត់ព្រំដែនសមុទ្រ រវាង ព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋសង្គមនិយមវៀតណាម

សម័យប្រជុំពេញអង្គរដ្ឋសភា ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១២

---

*- សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា*

*- ឯកឧត្តម លោកជំទាវ សមាជិក សមាជិកានៃរដ្ឋសភាដ៏ឧត្តុង្គឧត្តម*

*- ឯកឧត្តម លោកជំទាវ សមាជិក សមាជិកានៃរាជរដ្ឋាភិបាល*

*- ឯកឧត្តម លោកជំទាវ លោក លោកស្រី ទាំងអស់ជាទីមេត្រី !*

ថ្ងៃនេះ ខ្ញុំពិតជាមានកិត្តិយសដ៏ខ្ពង់ខ្ពស់ ដោយបានមករាយការណ៍ធ្វើបទបង្ហាញជូនដល់អង្គរដ្ឋសភាដ៏ឧត្តុឧត្តមនៃយើង លើបញ្ហាពាក់ព័ន្ធនឹងការងារបោះបង្គោលខណ្ឌសីមាព្រំដែនគោក និង ការកំណត់ព្រំដែនសមុទ្ររវាងព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋ សង្គមនិយមវៀតណាម ។

ជាបឋម ខ្ញុំសូមយកឱកាសនេះ ថ្លែងអំណរគុណចំពោះ ឯកឧត្តម **សុន ឆ័យ** តំណាងរាស្ត្រមណ្ឌលភ្នំពេញនៃគណបក្សសមរង្ស៊ី រួមជាមួយនឹងតំណាងរាស្ត្រដទៃទៀតនៃគណបក្សសមរង្ស៊ី ដែលបានលើកសំណួរមកកាន់រាជរដ្ឋាភិបាល ស្តីពីបញ្ហាព្រំដែនរវាងកម្ពុជា និង វៀតណាម ដែលជាបញ្ហាដ៏មានសារៈសំខាន់សម្រាប់អាយុជីវិតរបស់ជាតិទាំងមូល ។ ថ្វីត្បិតតែជារួម សំណួរទាំងអស់នេះ មានលក្ខណៈជាការចោទប្រកាន់មកលើរាជរដ្ឋាភិបាល ក្នុងគោលបំណងញុះញង់ធ្វើឱ្យមានការភាន់ច្រឡំ នៅក្នុងចំណោមសាធារណមតិជាតិ និង អន្តរជាតិ ដើម្បីកេងចំណេញខាងនយោបាយ ក៏ប៉ុន្តែខ្ញុំយល់ថា ការដែលឯកឧត្តម **សុន ឆ័យ** លេងល្បែងនយោបាយ តាមរយៈយន្តការប្រជាធិបតេយ្យឆ្លងតាមស្ថាប័នរដ្ឋសភារបស់យើងនេះ វានៅតែជាប្រការដែលល្អប្រសើរជាងការប្រព្រឹត្តិរបស់ប្រធានគណបក្សឯកឧត្តម ពោលគឺ ឯកឧត្តម **សម រង្ស៊ី** ដែលបានដើរទៅដកបង្គោលតម្រុយព្រំដែនដោយខុសច្បាប់នោះដែរ ។ ដូច្នេះ នេះ គឺជាមូលហេតុដ៏សំខាន់មួយ ដែលតម្រូវឱ្យខ្ញុំមកផ្តល់ការបំភ្លឺដោយផ្ទាល់នៅចំពោះអង្គរដ្ឋសភានៃយើងនាថ្ងៃនេះ ទោះបីថា វាមិនមែនជាមូលហេតុតែមួយគត់ និង សំខាន់ជាងគេនោះក៏ដោយ ។

ជាការពិត សំណួររបស់ឯកឧត្តម **សុន ឆ័យ** តំណាងរាស្ត្រមណ្ឌលភ្នំពេញ ពុំមានអ្វីប្លែកទេ ។ គេធ្លាប់បានដឹង និង ឮដដែលៗ ច្រើនដងមកហើយ នូវអ្វីដែលឯកឧត្តម **សុន ឆ័យ** និង សហសេវិករបស់ឯកឧត្តមនៅក្នុងគណបក្សសមរង្ស៊ី បានលើកឡើងជាញឹកញាប់មកនោះ ។ ទោះបីជាពេលខ្លះ សំណួរ និង ការចោទប្រកាន់ទាំងនោះ ត្រូវបានតាក់តែងឡើងតាមរូបភាពខុសគ្នាបន្តិចបន្តួច ក៏ប៉ុន្តែ គំនិតដើមរបស់វានៅតែ

ដដែល ហើយវាប្រែក្លាយទៅជាអ្វីមួយដែលពុំចាំបាច់រកខុសត្រូវទៀតទេ ព្រោះវាត្រូវតែអញ្ចឹង ពោលគឺ វាជាការសន្និដ្ឋាន ឬសន្ទតិជាមុន ឬជាការពិតមួយដែលត្រូវបានកំណត់ជាអត្តនោមតិ ដោយឯកឧត្តម **សុន ឆ័យ** និង សហសេរីករួចទៅហើយ ហើយគ្មាននណារអាចកែប្រែបាននោះឡើយ ។ ជារួម អ្វីដែលឯកឧត្តម **សុន ឆ័យ** បានលើកឡើងដដែលៗជារឿយៗនោះ នៅតែវិលវល់ជុំវិញគំនិតស្នេហាជាតិតាមរបៀបក្រុមខ្លួន ដែលថា រាជរដ្ឋាភិបាល ÷

- ធ្វើកិច្ចការព្រំដែនដោយពុំមានតម្លាភាព ពុំមានវត្តមាន ឬការចូលរួមពីអង្គការក្រៅរដ្ឋាភិបាល ឬ ពីគណបក្សប្រឆាំង ឬ អ្នកសង្កេតការណ៍អន្តរជាតិ ជាដើម នៅក្នុងគណៈកម្មាធិការព្រំដែនជាតិ
- ធ្វើតាមគំនាបរបស់វៀតណាម ដែលបង្គាប់ឱ្យធ្វើតែប៉ុណ្ណោះ
- ហាក់ដូចជាមានការបិទបាំងមិនឱ្យសាធារណៈជនបានដឹងឮ ដោយធ្វើការរា-រាំងមិនឱ្យបក្សប្រឆាំងបានចូលទៅមើលទីតាំងបង្គោលតម្រុយព្រំដែន ដោយប្រើកម្លាំងរារាំងគ្រប់បែបយ៉ាង រួមទាំងការចាប់ចង និង ដាក់គុកច្រវ៉ាក់ទៀតផង
- ធ្វើកិច្ចការព្រំដែនពុំស្មើភាពគ្នា ដោយទុកឱ្យប្រទេសជិតខាងជាអ្នកធ្វើ ឱ្យគេចូលមកបោះបង្គោលស្រេចតែចិត្ត លើដីស្រែចំការរបស់ប្រជាពលរដ្ឋខ្មែរ និងខ្វះធនធាន មនុស្សខ្វះឧបករណ៍ប្រើប្រាស់ ដែលជាប្រការធ្វើឱ្យកម្ពុជា បាត់បង់ទឹកដីជាច្រើនសន្ធឹកសន្ធាប់ទាំង ១០ ខេត្ត គឺតាំងពីខេត្តរតនគិរី ដល់ខេត្តកំពត គិតជាផ្ទៃដីរាប់ពាន់គីឡូម៉ែត្រក្រឡា និង បាត់ដែន សមុទ្រខ្មែរទៅឱ្យប្រទេសជិតខាង ក្នុងទំហំដ៏ធំ ដែលជាអំពើក្បត់ជាតិពុំអាចអត់អោនឱ្យបាន ហើយដែលគណបក្សរបស់ឯកឧត្តមសន្យាថា នឹងសើរើកិច្ចព្រមព្រៀងព្រំដែនដែលបានសម្រេចរួចមកហើយ ដោយទាមទារយកមកវិញនូវទឹកដីដែលបាត់ទៅនោះ ខណៈដែលខ្លួនបានឡើងកាន់អំណាច ជាដើម ។ល។

អង្គរដ្ឋសភាទាំងមូលពិតជានៅចាំបានថា នេះមិនមែនជាលើកទីមួយទេ ដែលរាជរដ្ឋាភិបាលបានផ្ដល់ការបំភ្លឺជាលាយល័ក្ខអក្សរ ឬ ចាត់តំណាងចូលមកផ្ដល់ការបំភ្លឺជូនដល់អង្គរដ្ឋសភាអំពីកិច្ចការដ៏មានសារសំខាន់ជាអាយុជីវិតនៃប្រទេសជាតិនេះ ។ នៅពេលនេះ ខ្ញុំក៏ប្រមូលចងក្រងយកមកជាមួយនូវការបំភ្លឺជាលាយល័ក្ខអក្សរទាំងនោះ

ផងដែរ ។ យ៉ាងណាក៏ដោយ ការឃោសនា និង សំណួរចោទប្រកាន់ជាអកុសល នៅតែបន្តកើតមានឡើង ហើយហាក់ដូចជាមានលក្ខណៈកាន់តែស្រួចស្រាវឡើងថែមទៀត ដោយសារអ្នកចោទសួរទាំងនោះ ធ្វើជាមិនយល់អំពីការខិតខំបំភ្លឺ និង ធ្វើជាមើលមិនឃើញអំពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល នៅក្នុងការដោះស្រាយបញ្ហាដ៏មានសារសំខាន់នេះឡើយ ។

ខ្ញុំពិតជាយល់ច្បាស់ដោយគ្មានការស្រមើស្រមៃទេថា ឯកឧត្តម **សុន ឆ័យ** និង សហសេរីករបស់ខ្លួន មានបំណងចង់យកបញ្ហាព្រំដែនដែលជាបញ្ហារសើបបំផុតសម្រាប់ប្រទេសជាតិ មកធ្វើអាជីវកម្មនយោបាយ ក្នុងគោលដៅវាយប្រហារមកលើគណបក្សប្រជាជនកម្ពុជា ពិសេសមកលើរូបខ្ញុំផ្ទាល់ ដើម្បីផលប្រយោជន៍នយោបាយរបស់ខ្លួន ។ នេះ មិនមែនជារឿងប្លែក និង ថ្មីសម្រាប់កម្ពុជានោះទេ ។ យុទ្ធសាស្ត្របែបនេះ ធ្លាប់ត្រូវបានគេយកមកប្រើរួចមកហើយ នៅក្នុងប្រវត្តិសាស្ត្រនយោបាយរបស់កម្ពុជា ។ យើងទាំងអស់គ្នានៅចាំបានថា នៅដើមទសវត្សឆ្នាំ ១៩៧០ ចរន្តនយោបាយសាធារណ-រដ្ឋ ដឹកនាំដោយលោកសេនាប្រមុខ **លន់ នល់** បានប្រើប្រាស់ការចោទប្រកាន់លើព្រះករុណា សម្តេចព្រះ **នរោត្តម សីហនុ** ដែលជាព្រះប្រមុខរដ្ឋនៅពេលនោះថា ***«លក់ទឹកដីឱ្យយួន»*** ជាលេសមួយដ៏សំខាន់សម្រាប់ការធ្វើរដ្ឋប្រហារទម្លាក់ព្រះអង្គ រហូតដល់មានការតែងជាចម្រៀងចាក់ផ្សាយជាសាធារណៈថែមទៀតផង ។

នៅពេលនេះ ឯកឧត្តម **សុន ឆ័យ** និង សហសេរីកអាចចង់ប្រើប្រាស់យុទ្ធសាស្ត្រនៃការឃោសនានយោបាយដដែលនេះ ដើម្បីផ្តួលគណបក្សប្រជាជនកម្ពុជា ពិសេសគឺផ្តួលរូបខ្ញុំផ្ទាល់ ដែលជាមេដឹកនាំសំខាន់មួយរូបនៅក្នុងគណបក្សប្រជាជនកម្ពុជានេះ ។ ដូច្នេះ បើទោះបីជាខ្ញុំ ក្នុងឋានៈជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា មកបំភ្លឺដោយផ្ទាល់ លើសំណួររបស់ឯកឧត្តម **សុន ឆ័យ** នៅពេលនេះទៀត ក៏ប្រហែលជាឯកឧត្តម **សុន ឆ័យ** និង សហសេរីករបស់ខ្លួន នៅតែធ្វើជាមិនយល់ដដែលដែរ ។ លើសពីនេះទៀត ឯកឧត្តម **សុន ឆ័យ** និង សហសេរីក អាចនឹងមិនចង់ស្តាប់ការ-ពន្យល់នេះទេ ហើយអាចនាំគ្នាដើរចេញពីការប្រជុំនេះថែមទៀតផង ។ ខ្ញុំសូមអំពាវនាវដល់ ឯកឧត្តម **សុន ឆ័យ** និង សហសេរីក សូមមេត្តាអត់ធ្មត់ទ្រាំនៅស្តាប់ការពន្យល់បំភ្លឺរបស់រាជរដ្ឋាភិបាល ទៅលើសំណួររបស់ឯកឧត្តមឱ្យបានដល់ចប់ ទោះបីជាការ-ពន្យល់បង្ហាញអំពីការពិតនេះ អាចមិនពិរោះសម្រាប់ឯកឧត្តម និង សហសេរីក ឬក៏ឯកឧត្តម និង សហសេរីក អាចមិនចង់ស្តាប់ មិនចង់ទទួលយកក៏ដោយ ។

យ៉ាងណាមិញ ខ្ញុំសូមអនុញ្ញាតគូសបញ្ជាក់ថា កិច្ចការការពារអធិបតេយ្យ និង បូរណភាពទឹកដីរបស់ជាតិ គឺជាភារកិច្ច និងកាតព្វកិច្ច សំខាន់ជាងគេ និងមុនគេបង្អស់ របស់រាជរដ្ឋាភិបាល ហើយក៏ជាសិទ្ធិ និង ករណីយកិច្ចរបស់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប ផងដែរ ។ ការស្នេហាជាតិ និង ទឹកដីនេះ គឺពុំមែនជាសិទ្ធិផ្តាច់មុខរបស់បុគ្គល ឬគណ-បក្សនយោបាយណាមួយតែម្នាក់ឯងនោះទេ ។ ក៏ប៉ុន្តែ ផ្ទុយទៅវិញ ការលើកយកបញ្ហា នេះមកធ្វើអាជីវកម្មកេងចំណេញខាងនយោបាយ ដោយគ្មានការទទួលខុសត្រូវ ដើម្បី បម្រើផលប្រយោជន៍របស់បុគ្គល ក្រុម ឬ គណបក្សរបស់ខ្លួន តាមរយៈមធ្យោបាយ ប្រជាភិថុត ការញុះញង់ ការបំផ្លើស និង ការបង្កើតឱ្យមានការភាន់ច្រឡំ លើបញ្ហា ព្រំដែននេះ នៅក្នុងចំណោមសាធារណមតិជាតិ និងអន្តរជាតិ អាចនឹងនាំមកនូវគ្រោះ-ថ្នាក់ដ៏ធំធេងសម្រាប់ប្រទេសជាតិ និង ប្រជាជនទៅវិញទេ ។ បទពិសោធន៍របស់កម្ពុជា ខ្លួនឯងផ្ទាល់ និង របស់បណ្តាប្រទេសផ្សេងទៀតជាច្រើន បានបង្ហាញឱ្យឃើញថា ទង្វើ ដោយគ្មានការទទួលខុសត្រូវបែបនេះ អាចនាំមកនូវអរិភាពជាតិសាសន៍ បង្ករការខូច ខាតដល់ទំនាក់ទំនងមិត្តភាព សហប្រតិបត្តិការ និង អ្នកជិតខាងល្អ រវាងប្រទេសជាប់ ព្រំដែនគ្នា ហើយជារឿយៗ អាចនាំទៅដល់ការកើតឡើងនូវជម្លោះរវាងប្រទេស និង ប្រទេស អស្ថិរភាពផ្ទៃក្នុង និង ការបាត់បង់នូវផលប្រយោជន៍សង្គម- សេដ្ឋកិច្ចជាច្រើន ផ្សេងទៀតរបស់ជាតិ និង ប្រជាជន ។

ខាងលើនេះ គឺជាមូលហេតុចម្បង និង សំខាន់ជាងគេ ដែលជំរុញឱ្យខ្ញុំសម្រេចចិត្ត ថា ត្រូវតែមកផ្តល់ការបំភ្លឺដោយផ្ទាល់នៅក្នុងសម័យប្រជុំរដ្ឋសភាលើកនេះ ទៅលើ សំណួររបស់ឯកឧត្តម **សុន ឆ័យ** ទោះបីជាបានដឹងមុនថា ឯកឧត្តមមិនមានចេតនាចង់ ស្តាប់ការពន្យល់បំភ្លឺនេះក៏ដោយ ។ គោលដៅចម្បងនៅទីនេះ គឺការផ្តល់នូវការពន្យល់ បូកសរុបគ្រប់ជ្រុងជ្រោយមួយ អំពីគោលនយោបាយ និង កិច្ចខិតខំប្រឹងប្រែង ប្រកប ដោយឆន្ទៈមោះមុត និង ក្នុងស្មារតីប្តូរប្តេជ្ញឥតងាករេរបស់រាជរដ្ឋាភិបាល ក្នុងការដោះ-ស្រាយបញ្ហាព្រំដែនរវាងកម្ពុជា និង វៀតណាម ជូនដល់អង្គរដ្ឋសភាទាំងមូលជ្រាប និង តាមរយៈអង្គរដ្ឋសភាដ៏ឧត្តុងឧត្តមនៃយើងនេះ ជូនដល់ប្រជាជនកម្ពុជាគ្រប់ស្រទាប់ជាន់ ថ្នាក់ ទាំងនៅក្នុង និង ក្រៅប្រទេស ជ្រាប សំដៅជម្រះនូវភាពមិនច្បាស់លាស់ទាំង-ឡាយនៅក្នុងកិច្ចការដ៏មានសារសំខាន់នេះ ក៏ដូចជារំលេចឱ្យឃើញផងដែរ នូវគោល-បំណង និង ផលប្រយោជន៍នយោបាយនានា ដែលលាក់បង្កប់នៅពីក្រោយការចោទ ប្រកាន់ និង ការឃោសនាញុះញង់ដដែលៗឥតឈប់ឈរពាក់ព័ន្ធនឹងបញ្ហានេះ ។

- **សម្តេចចក្រី ប្រធានរដ្ឋសភា**
- **ឯកឧត្តម លោកជំទាវ លោក លោកស្រី !**

តទៅទៀតនេះ ដើម្បីអង្គរដ្ឋសភាទាំងមូល និង ជនរួមជាតិគ្រប់រូប បានជ្រាបច្បាស់អំពីការពិត ខ្ញុំសូមអនុញ្ញាតធ្វើបទបង្ហាញស្តីពីការបោះបង្គោលខណ្ឌសីមាព្រំដែនគោក និង ការកំណត់ព្រំដែនសមុទ្រ រវាងកម្ពុជា និងវៀតណាម ដែលមានតាមលំដាប់លំដោយ ដូចខាងក្រោម ÷

## I- **អំពីព្រំដែនគោក**

### **ទី១ - ទិដ្ឋភាពទូទៅ:**

យើងទាំងអស់គ្នាបានដឹង និង ចាំរត់មាត់គ្រប់គ្នាហើយថា ប្រទេសកម្ពុជាមានផ្ទៃដី ១៨១ ០៣៥ គីឡូម៉ែត្រក្រឡា និង មានព្រំប្រទល់ ជាប់ជាមួយនឹងប្រទេសជិតខាងបី គឺ ប្រទេសឡាវ ប្រទេសវៀតណាម និង ប្រទេសថៃ ។ ចំនួនផ្ទៃដីនេះ បើសិក្សាឱ្យល្អិតល្អន់ទៅ យើងនៅពុំទាន់ដឹងច្បាស់ថា តើគេគណនាតួលេខនេះឡើងតាមរបៀបណាទេ ។ តាមការប៉ាន់ស្មាន ប្រហែលជាគេយកផ្ទៃក្រឡាដីនៃខេត្តទាំងអស់ មកបូកបញ្ចូលគ្នា បានទៅជាផ្ទៃក្រឡាដីមួយ ដែលយើងដឹង និង ចេះចាំមាត់សព្វថ្ងៃនេះ ។ ការគណនាកាលនោះ ប្រហែលជាត្រូវបានធ្វើឡើងលើមូលដ្ឋានខ្សែព្រំដែនបន្សល់ទុកដោយអាណា-ព្យាបាលបារាំង ដែលបច្ចេកវិទ្យានៃការផលិតផែនទីព្រំដែននាពេលនោះ នៅមានកម្រិតអន់ថយនៅឡើយ ជាប្រភេទផែនទីចាស់យូរឆ្នាំ ហើយថានលេខា ក៏មានការប្រែប្រួលជាបន្តបន្ទាប់ ដែលបង្ករឱ្យមានភាពខុសគ្នារវាងផែនទី និង ដីជាក់ស្តែង ។

ជាការពិត ជាមួយនឹងភាពជឿនលឿននៃបច្ចេកវិទ្យា ការគណនាដោយប្រើកម្មវិធីកុំព្យូទ័រលើមូលដ្ឋាននៃផែនទីដែលមានស្រាប់ បានផ្តល់ជាតួលេខទំហំផ្ទៃក្រឡានៃព្រះ-រាជណាចក្រកម្ពុជាមួយចំនួនផ្សេងទៀត ដែលធំជាងតួលេខ ១៨១ ០៣៥ គីឡូម៉ែត្រក្រឡានេះទៅទៀត ។ ខ្ញុំនឹងធ្វើការឆ្លុះបញ្ចាំងថែមទៀត អំពីបញ្ហាតួលេខនេះ នៅក្នុងផ្នែកខាងក្រោម ។

### **ទី២ - ទិដ្ឋភាពច្បាប់ និង ប្រវត្តិសាស្ត្រ:**

ជារួម បារាំងក្នុងឋានៈជាអាណាព្យាបាលលើកម្ពុជាអស់រយៈពេល ៩០ ឆ្នាំ (១៨៦៣-១៩៥៣) បានបន្សល់ទុកឱ្យកម្ពុជានូវព្រំដែនមួយដែលមិនទាន់ច្បាស់លាស់នៅឡើយ ទាំងព្រំដែនគោក ទាំងព្រំដែនសមុទ្រ ។ នៅក្នុងសម័យកាលនោះ ព្រំដែន

រវាងកម្ពុជា- ថៃ ត្រូវបានទទួលស្គាល់ជាព្រំដែនអន្តរជាតិ ដែលមានទាំងបង្គោលព្រំដែនចំនួន ៧៣ ត្រូវបានបោះរួចនៅលើដីដោយគណៈកម្មការចម្រុះកំណត់ព្រំដែនរវាងឥណ្ឌូចិន និង សៀម ។ រីឯព្រំដែនកម្ពុជា- ឡាវ គឺជាព្រំដែនរដ្ឋបាលសុទ្ធសាធ ដែលត្រូវបានកំណត់ឡើងដោយសេចក្តីសម្រេចរបស់អគ្គទេសាភិបាលរបស់បារាំង នៅហាណូយ ។

ចំពោះដែនដីកូសាំងស៊ីន គឺជាទឹកដីរបស់អាណានិគមបារាំង ហើយរដ្ឋបាលអាណាព្យាបាលបារាំងនៅកម្ពុជា គ្រាន់តែជារដ្ឋបាលចំណុះឱ្យទេសាភិបាលបារាំង នៅកូសាំងស៊ីនតែប៉ុណ្ណោះ ។ ព្រំដែនរវាងកម្ពុជា និង កូសាំងស៊ីន ត្រូវបានកំណត់ឡើងតាមសេចក្តីសម្រេចស្តីពីការកំណត់ព្រំដែន ឆ្នាំ ១៨៧០ និង អនុសញ្ញាកំណត់ព្រំដែនឆ្នាំ ១៨៧៣ រវាងព្រះមហាក្សត្រ ព្រះបាទ **នរោត្តម** ជាមួយនឹងទេសាភិបាលកូសាំងស៊ីន ហើយថែមទាំងបានបោះបង្គោលព្រំដែននៅលើដីបាន ចំនួន ១២៤ បង្គោលទៀតផង (សូមមើលផែនទី ក្នុងឧបសម្ព័ន្ធទី ១) ។ ហេតុដូច្នេះហើយ យើងអាចចាត់ទុកបានថា ព្រំដែនកម្ពុជា- កូសាំងស៊ីន គឺជាព្រំដែនអន្តរជាតិ ។ រីឯព្រំដែនកម្ពុជា- អាណ្ណាមវិញ ត្រូវបានធ្វើឡើងតាមសេចក្តីសម្រេចឯកតោភាគី ដោយមិនមានការឯកភាពពីកម្ពុជាទេ។ បន្ថែមពីលើនេះទៀត ក៏នៅពុំទាន់មានបង្គោលព្រំដែនណាមួយត្រូវបានបោះនៅលើដីជាក់ស្តែងនៅឡើយដែរ ។ ដូច្នេះ យើងអាចចាត់ទុកបានថា ព្រំដែនកម្ពុជា- អាណ្ណាម គឺជាព្រំដែនរដ្ឋបាលប៉ុណ្ណោះ ។

ដូច្នេះ អ្វីដែលកម្ពុជាទទួលបាននៅពេលដែលអាណាព្យាបាលរបស់បារាំង ត្រូវបានបញ្ចប់នៅឆ្នាំ ១៩៥៣ គឺខ្សែបន្ទាត់ព្រំដែនមួយដែលមិនច្បាស់លាស់ និង ពុំទាន់មានការបោះបង្គោលព្រំដែនឱ្យបានត្រឹមត្រូវតាមនីតិវិធីច្បាប់ ក៏ដូចជាតាមបែបបទបច្ចេកទេសនៅឡើយ ក្រៅពីបង្គោលព្រំដែនចំនួន ១២៤ ដែលអាណាព្យាបាលបារាំងបានបោះរវាងកម្ពុជា និង កូសាំងស៊ីន នាសតវត្សរ៍ទី ១៩ និង ដើមសតវត្សរ៍ទី ២០ ។ បន្ថែមទៅលើនេះទៀត អាណាព្យាបាលបារាំងបានធ្វើការផ្លាស់ប្តូរទីតាំងបង្គោលព្រំដែនមួយចំនួន និង កែខ្សែព្រំដែនជាច្រើនលើក ច្រើនសារ ដោយពុំបានធ្វើការពិគ្រោះយោបល់ និង បានការឯកភាពពីប្រទេសដែលខ្លួនគ្រប់គ្រងនោះឡើយ ។ ការពុំបានដឹង ឬស្គាល់ច្បាស់ពីព្រំដែនរបស់ខ្លួននេះ បានក្លាយទៅជាមូលហេតុចម្បងមួយដែលនាំឱ្យមានជម្លោះព្រំដែនមិនចេះចប់ មិនចេះហើយ រវាងអាជ្ញាធរមូលដ្ឋាននៃប្រទេសទាំងពីរ ក៏ដូចជារវាងប្រជាជនកម្ពុជា និង ប្រជាជនវៀតណាម ដែលពុំបានដឹងពីការកែសម្រួលផ្លាស់ប្តូរខ្សែ

ព្រំដែននេះ ហើយនៅតែបន្តការគ្រប់គ្រងកាន់កាប់ប្រើប្រាស់ដីធ្លីរៀងៗខ្លួន តាមទំនៀមទម្លាប់ ដែលមានពីមុនៗមកនោះ ។

នេះ គឺជាមរតកប្រវត្តិសាស្ត្រ ដែលកម្ពុជាទទួលបានពីអាណាព្យាបាលបារាំង ហើយត្រូវទទួលបន្ទុកដោះស្រាយដោយខ្លួនឯងបន្តទៅទៀត បន្ទាប់ពីបារាំងបានចាកចេញពីឥណ្ឌូចិនទៅ ។ នៅលើមូលដ្ឋាននៃមរតកប្រវត្តិសាស្ត្របែបនេះ តើគេត្រូវចាប់ផ្ដើមពីចំណុចណានៅក្នុងការកំណត់ខ្សែព្រំដែន និង ក្នុងការពារបូរណភាពទឹកដីរបស់កម្ពុជា ? តើគេត្រូវទទួលយកខ្សែព្រំដែនដែលបារាំងបន្សល់ទុកឱ្យ ឬត្រូវធ្វើសង្គ្រាមដើម្បីសើរើខ្សែព្រំដែន ?

ក្រោយពីកម្ពុជាទទួលបានឯករាជ្យភ្លាម ព្រះករុណាព្រះបាទ សម្ដេចព្រះ **នរោត្ដម សីហនុ** បានដឹកនាំចលនាជាតិដ៏ខ្លាំងក្លាមួយ ដើម្បីអំពាវនាវឱ្យសហគមន៍អន្តរជាតិទទួលស្គាល់ព្រំដែនកម្ពុជា ដោយឈរលើគោលការណ៍ ***«ខ្សែព្រំដែនមិនកែប្រែ» (Uti Possidetis)*** ។ ជាការពិត គោលការណ៍ខ្សែព្រំដែនមិនកែប្រែនេះ មានសារសំខាន់ខ្លាំងណាស់ សម្រាប់ការបន្តដោះស្រាយបញ្ហាព្រំដែនដ៏ស្មុគ្រស្មាញរវាងបណ្ដាប្រទេសនៅក្នុងអតីតឥណ្ឌូចិន ពីព្រោះ វាជួយបញ្ចៀសបាននូវសង្គ្រាមដែលអាចកើតមានឡើងដោយបញ្ហាទំនាស់ព្រំដែននេះ បើទោះជាមានមតិខ្លះមិនទទួលយកគោលការណ៍នេះក៏ដោយ ។ ជាទូទៅ ប្រទេសជាច្រើនដែលបានរួចផុតពីរបបអាណានិគម ហើយត្រូវជួបប្រឈមនឹងបញ្ហាព្រំដែនដូចនេះ តែងតែទទួលយកគោលការណ៍ដ៏មានសារសំខាន់នេះមកអនុវត្ត ដើម្បីបន្តដោះស្រាយបញ្ហាព្រំដែនជាមួយគ្នា ដោយរក្សាបាននូវសុខសន្តិភាព និង ទំនាក់ទំនងជាអ្នកជិតខាងល្អ ។

ជាលទ្ធផល ជម្លោះលើការជ្រើសរើសយកគោលការណ៍ខ្សែព្រំដែនមិនកែប្រែរវាងកម្ពុជា និង វៀតណាម ត្រូវបានបញ្ចប់នៅឆ្នាំ ១៩៦៤ នៅពេលដែលសម្ដេចព្រះ **នរោត្ដម សីហនុ** ព្រះប្រមុខរដ្ឋនាពេលនោះ បានយកផែនទីបោន (Bonne) ខ្នាត ១/១០០ ០០០ បោះពុម្ពដោយក្រុមភូមិសាស្ត្រឥណ្ឌូចិន ទៅតម្កល់ទុកនៅអង្គការសហប្រជាជាតិ ហើយតាមរយៈនេះ ព្រះអង្គបានអំពាវនាវឱ្យមានការធានារ៉ាប់រងពីសំណាក់មហាអំណាចនានា ក្នុងការគោរពបូរណភាពទឹកដីកម្ពុជាតាមផ្លូវច្បាប់អន្តរជាតិ និង ឱ្យទទួលស្គាល់ ព្រមទាំងគោរពឯករាជ្យ អព្យាក្រឹត្យភាព បូរណភាពទឹកដីកម្ពុជា ក្នុងរង្វង់ខ្សែព្រំដែនបច្ចុប្បន្ន ដោយបានប្រកាសដាច់ខាតថា មិនអាចរុះរើ និង កែប្រែបានឡើយ ។ ក្រោមការអំពាវនាវនេះ ប្រទេសជាច្រើន ជាពិសេសគឺប្រទេសសាមីដែល

មានការពាក់ព័ន្ធ បានប្រកាសទទួលស្គាល់ និង សន្យាគោរពបូរណភាពទឹកដីកម្ពុជា ក្នុងរង្វង់ខ្សែព្រំដែនបច្ចុប្បន្ន (សូមមើលផែនទី ក្នុងឧបសម្ព័ន្ធទី ២) ។

ទន្ទឹមនឹងនេះ ក៏គួរកត់សម្គាល់ផងដែរថា បន្ទាប់ពីកម្ពុជាប្រកាសទទួលយកគោលការណ៍ ***«ខ្សែព្រំដែនមិនកែប្រែ»*** នៅពេលដែលកម្ពុជាបានឯករាជ្យនាឆ្នាំ ១៩៥៣ និង បន្ទាប់ពីកម្ពុជាបានយកផែនទីទៅតម្កល់នៅអង្គការសហប្រជាជាតិ និង ប្រកាសឱ្យអន្តរជាតិទទួលស្គាល់នោះមក សិទ្ធិទាមទារទឹកដីជូនតានៅកម្ពុជាក្រោមនោះ ក៏ត្រូវបានផុតរលត់ទៅដែរ ដោយសារថា កូសាំងស៊ីន (ទឹកដីកម្ពុជាក្រោម) ត្រូវបានកំណត់ថាជាទឹកដីរបស់វៀតណាមរួចអស់ទៅហើយ តាមរយៈសេចក្តីសម្រេចស្តីពីការកំណត់ព្រំដែនឆ្នាំ ១៨៧០ និង អនុសញ្ញាកំណត់ព្រំដែនឆ្នាំ ១៨៧៣ ហើយថែមទាំងបានបោះបង្គោលព្រំដែននៅលើដីបានចំនួន ១២៤ បង្គោលទៀតផង ដូចបានជម្រាបជូនពីខាងលើ ។ ដូច្នេះ គេមិនត្រូវទម្លាក់កំហុសទៅលើព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ឡើយ អំពីការបោះបង់សិទ្ធិទាមទារទឹកដីកម្ពុជាក្រោមនេះ ពីព្រោះនៅក្នុងកាលៈទេសៈគ្រានោះ កម្ពុជាគ្មានជម្រើសអ្វីប្រសើរជាងការទទួលស្គាល់នូវមរតកព្រំដែន ដែលអាណាព្យាបាលបារាំងបានបន្សល់ទុកឱ្យនោះទេ ។

ចំណេរតមកទៀត រដ្ឋាភិបាលក្នុងរបបជាបន្តបន្ទាប់ដែលគ្រប់គ្រងកម្ពុជា បានបន្តទទួលយកគោលការណ៍ ***«ខ្សែព្រំដែនមិនកែប្រែនៅពេលដែលកម្ពុជាបានឯករាជ្យ»*** មកអនុវត្ត ក្នុងការរកដំណោះស្រាយព្រំដែនរវាងកម្ពុជាជាមួយនឹងប្រទេសជិតខាងទាំងបី លើកលែងតែរបបសាធារណរដ្ឋខ្មែរ ដឹកនាំដោយលោកសេនាប្រមុខ **លន់ នល់** មួយប៉ុណ្ណោះ ដែលបានបន្តយកគោលការណ៍ខ្សែព្រំដែនមិនកែប្រែនេះ មកអនុវត្តន៍ចំពោះតែព្រំដែនគោក រីឯព្រំដែនសមុទ្រវិញ សាធារណរដ្ឋខ្មែរបានគូសខ្សែថ្មីមួយដោយព័ទ្ធយកទាំងកោះត្រល់ និង កោះថ្ងូ ព្រមទាំងទឹកសមុទ្រមួយចំនួនទៀតបន្ថែមក្នុងទឹកដីកម្ពុជា ដែលយើងហៅខ្សែនោះថា ***«ខ្សែឆ្នាំ ១៩៧២»*** ។ ដូចយើងបានឃើញស្រាប់ការញុះញង់បង្កើតស្មារតីជាតិនិយមជ្រុល និង បំណងសើរើព្រំដែន ដែលជាមរតកប្រវត្តិសាស្ត្រដោយគ្មានការទទួលខុសត្រូវ ដែលក្រុមអ្នកនយោបាយសាធារណរដ្ឋដឹក-នាំដោយសេនាប្រមុខ **លន់ នល់** បានបំផុសឡើងនោះ មិនបានផ្តល់ផលល្អអ្វីដល់

ប្រទេសជាតិ និង ប្រជាជនកម្ពុជា ក្រៅពីភ្នក់ភ្លើងសង្គ្រាម និង ការវិនាសហិចហោច នោះទេ ។ នេះ គឺជាមេរៀនប្រវត្តិសាស្ត្រដ៏សំខាន់មួយដែលអ្នកនយោបាយជំនាន់ក្រោយ រួមបញ្ចូលទាំងឯកឧត្តម **សុន ឆ័យ** និង សហសេរីក ព្រមទាំងមជ្ឈដ្ឋានមួយ-ចំនួនទៀតផងដែរ ដែលមិនទាន់បានបោះបង់ចោលនូវគំនិតនេះ ត្រូវដកស្រង់យកមកធ្វើជាបទពិសោធន៍ ប្រសិនបើគេចង់ចូលរួមក្នុងកិច្ចដំណើរការនយោបាយក្នុងប្រទេស ប្រកបដោយការទទួលខុសត្រូវខ្ពស់ និងក្នុងស្មារតីស្ថាបនា និងស្នេហាជាតិពិតប្រាកដ ។

បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំទៅ នាខែ មករា ឆ្នាំ ១៩៧៩ និង ដោយផ្អែកលើបទពិសោធន៍នៃការឆ្លងកាត់របបនយោបាយជាច្រើន នៅក្នុងរយៈពេលចុងក្រោយនេះនៃប្រវត្តិសាស្ត្ររបស់ប្រទេសជាតិ កម្ពុជាពិតជាគ្មានជម្រើសអ្វីល្អប្រសើរជាងការ-ទទួលយកនូវមរតករបស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ពោលគឺ ***«គោលការណ៍ខ្សែព្រំដែនមិនកែប្រែនៅពេលកម្ពុជាបានឯករាជ្យ»*** នេះ មកអនុវត្តទាំងស្រុងនោះទេ ។ គឺមានតែគោលការណ៍នេះមួយគត់ ដែលអាចជួយឱ្យកម្ពុជាធានាបាននូវបូរណភាពទឹកដីរបស់ខ្លួន ដែលបានរង្គោះរង្គើដោយសារសង្គ្រាមស៊ីវិលរ៉ាំរ៉ៃកន្លងមក ។

លើមូលដ្ឋាននៃមរតកប្រវត្តិសាស្ត្រដ៏លំបាកស្មុគស្មាញនេះ រដ្ឋាភិបាលនៃសាធា-រណរដ្ឋប្រជាមានិតកម្ពុជានាពេលនោះ បានចុះកិច្ចព្រមព្រៀង និង សន្ធិសញ្ញាដែលទាក់ទងទៅនឹងព្រំដែនគោកចំនួន ៣ ជាមួយនឹងសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលខ្ញុំសូមធ្វើការពន្យល់ជូនដោយសង្ខេបនាពេលនេះ គឺ ÷

**- សន្ធិសញ្ញាស្តីពីគោលការណ៍ដើម្បីដោះស្រាយព្រំដែនគោក និង លក្ខន្តិកៈព្រំដែន ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៨៣ :**

ស្របតាមឯកសារទាំងពីរនេះ ភាគីទាំងសងខាងបានចាត់ទុកព្រំដែនមានរួចមកហើយ ដែលគូសនៅលើផែនទីខ្នាត ១/១០០ ០០០ របស់ក្រុមភូមិសាស្ត្រឥណ្ឌូចិន ដាក់ឱ្យប្រើប្រាស់មុនឆ្នាំ ១៩៥៤ ឬនៅកាលបរិច្ឆេទកៀកបំផុតទៅនឹងឆ្នាំ ១៩៥៤ ថាជាព្រំដែនរដ្ឋរវាងប្រទេសទាំងពីរ ។ ការកំណត់យកនេះ ស្របទៅនឹងគោលការណ៍ច្បាប់អន្តរជាតិស្តីពី ***«ខ្សែព្រំដែនមិនកែប្រែ»*** ហើយវាស្របទៅនឹងផែនទីដែលសម្តេចព្រះ

**នរោត្តម សីហនុ** បានតម្កល់ទុកនៅអង្គការសហប្រជាជាតិ នាឆ្នាំ ១៩៦៤ ។ម៉្យាងទៀត នៅត្រង់នេះ ខ្ញុំសូមធ្វើការកត់សម្គាល់ថា ការកំណត់យកផែនទីដែលត្រូវបានដាក់ឱ្យប្រើប្រាស់ នៅមុនឆ្នាំ ១៩៥៤ ឬនៅកាលបរិច្ឆេទកៀកបំផុតទៅនឹងឆ្នាំ ១៩៥៤ នេះ គឺជាគន្លឹះមួយដ៏សំខាន់ សម្រាប់ជួយកាត់បន្ថយគ្រោះថ្នាក់ផ្សារភ្ជាប់ទៅនឹងភាពចន្លោះប្រហោងនៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ដែលបានកំណត់យកកាលបរិច្ឆេទនេះ នៅចន្លោះឆ្នាំ ១៩៣៣-១៩៥៣ ។ ជារួម ការកំណត់កាលបរិច្ឆេទគោល ***«នៅមុនឆ្នាំ ១៩៥៤»*** ឬ ***«កៀកបំផុតទៅនឹងឆ្នាំ ១៩៥៤»*** នេះ អាចអនុញ្ញាតយើងប្រើប្រាស់ចំណុចនេះ ដើម្បីទាមទារឱ្យមានការពិនិត្យឡើងវិញនូវចំណុចព្រំដែនមួយចំនួន ដែលត្រូវបានកែប្រែនៅមុនឆ្នាំ ១៩៣៣ ។ ខ្ញុំនឹងផ្តល់ការបំភ្លឺថែមខ្លះទៀតលើភាពចន្លោះប្រហោងនៅក្នុងរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ ក្នុងផ្នែកដែលមានការពាក់ព័ន្ធនៅក្រោម ។

**- សន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋ ឆ្នាំ ១៩៨៥ :**

សន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋ ឆ្នាំ ១៩៨៥ នេះ បានយកគោលការណ៍ដូចដែលបានកំណត់ក្នុងសន្ធិសញ្ញាឆ្នាំ ១៩៨៣ ខាងលើ ដោយយកផែនទីខ្នាត ១/១០០ 000 របស់ក្រុមភូមិសាស្រ្តឥណ្ឌូចិន និង ផែនទី UTM ខ្នាត ១/៥០ 000 ដែលគូសខ្សែព្រំដែនចេញពីផែនទីបោន (Bonne) ខ្នាត ១/១០០ 000 SGI ធ្វើជាមូលដ្ឋានក្នុងការកំណត់ខ្សែព្រំដែនដីគោករវាងប្រទេសទាំងពីរ ។ សន្ធិសញ្ញានេះ គឺជាការបន្តអនុវត្តដោយឥតងាករេតាមគោលការណ៍ច្បាប់អន្តរជាតិស្តីពី ***«ខ្សែព្រំដែនមិនកែប្រែ»*** និង តាមបណ្តាផែនទី ដែលត្រូវបានប្រកាន់យកដោយសម្តេចព្រះ **នរោត្តម សីហនុ** ក្រោយពេលដែលកម្ពុជាបានចាកផុតពីអាណាព្យាបាលបារាំងមក ។

យ៉ាងណាក៏ដោយ កិច្ចព្រមព្រៀង និង សន្ធិសញ្ញាព្រំដែនទាំងអស់ខាងលើនេះ នៅតែត្រូវបានក្លាយទៅជាកម្មវត្ថុនៃការចោទប្រកាន់ ពីសំណាក់ក្រុមអ្នកនយោបាយដែលបានប្រកាសខ្លួនជា **«អ្នកស្នេហាជាតិ»** ពិតប្រាកដនោះ ថាបានធ្វើឱ្យកម្ពុជាបាត់បង់ទឹកដី ទាំងព្រំដែនគោក និង ព្រំដែនសមុទ្រ ហើយសំអាងលើមូលហេតុនេះ គេបានស្នើឱ្យរាជរដ្ឋាភិបាលបច្ចុប្បន្ន លុបចោលសុពលភាពនៃកិច្ចព្រមព្រៀង និង សន្ធិសញ្ញាព្រំដែនទាំងអស់នោះ ។ ចំណុចនេះ បើក្រឡេកមើលភ្លាមទៅឃើញថា អ្នកដែល

បានលើកសំណើនេះ មានគំនិតចង់វាយប្រហារខាងនយោបាយទៅលើរដ្ឋាភិបាលអតីតសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលជាអ្នកចុះហត្ថលេខាលើកិច្ចព្រមព្រៀង និងសន្ធិសញ្ញាព្រំដែនទាំងអស់នេះ ។ ក៏ប៉ុន្តែ បើពិនិត្យមើលឱ្យស៊ី ជម្រៅខាងខ្លឹមសារវិញ ឃើញថា គេហាក់ដូចជាមានបំណងវាយប្រហារទៅលើព្រះមហាវីរក្សត្រ សម្ដេចព្រះ **នរោត្តម សីហនុ** ទៅវិញទេ ពីព្រោះព្រះអង្គគឺជាវីរជនស្នេហាជាតិដ៏កំពូលរបស់កម្ពុជា ដែលបានប្រកាន់យកគោលការណ៍ ***«ខ្សែព្រំដែនមិនកែប្រែ»*** មកប្រើប្រាស់តាំងពីដើមទី និង បានកំណត់យកផែនទីដូចបានបញ្ជាក់ជូនខាងលើ ទៅដាក់តម្កល់នៅអង្គការសហ-ប្រជាជាតិថែមទៀតផង ។ នេះហើយគឺជាល្បិច ***«វាយ ហ៊ុន សែន ត្រូវ សីហនុ»*** ឬ ***«បាញ់ព្រួញមួយបានចាបពីរ»*** នោះ ។

**ទី៣- ការបន្តដោះស្រាយបញ្ហាព្រំដែនគោកជាមួយវៀតណាម ដោយរាជរដ្ឋាភិបាល:**

បន្ទាប់ពីរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិមួយ ត្រូវបានបង្កើតឡើងក្រោយឆ្នាំ ១៩៩៣ ដោយមានកិច្ចសហការលើផ្នែកបច្ចេកទេសពីបរទេសរួមជាមួយនឹងអ្នកជំនាញខាងព្រំដែនរបស់រាជរដ្ឋាភិបាល យើងបានធ្វើការសិក្សាលម្អិតលើឯកសារទាំងឡាយ ដែលពាក់ព័ន្ធដល់ការងារព្រំដែនកម្ពុជាជាមួយប្រទេសជិតខាងទាំងបី ទាំងព្រំដែនគោក ទាំងព្រំដែនសមុទ្រ ដែលពេលនេះ ខ្ញុំសូមលើកឡើងតែករណីជាមួយប្រទេសវៀតណាមមួយប៉ុណ្ណោះ ។ ផ្អែកលើការសិក្សាលម្អិតនេះ កម្ពុជាបានពិនិត្យឃើញនូវការចាំបាច់ត្រូវស្នើទៅរដ្ឋាភិបាលវៀតណាម សុំធ្វើការកែសម្រួល និង បំពេញបន្ថែម នូវចំណុចមួយចំនួនលើកិច្ចព្រមព្រៀង និង សន្ធិសញ្ញាដែលមានរួចហើយ ដើម្បីឱ្យសបទៅតាមគោលការណ៍ច្បាប់ជាតិ និង ច្បាប់អន្តរជាតិ ព្រមទាំងស្របតាមការអនុវត្តជាអន្តរជាតិ ។

ជារួម ការសិក្សាលម្អិតបានបង្ហាញឱ្យឃើញថា ផែនទីដែលតម្កល់នៅអង្គការសហប្រជាជាតិនាឆ្នាំ ១៩៦៤ គឺជាផែនទីចាស់ ដែលថានលេខានៅលើផែនទីនោះ មានការប្រែប្រួលអស់មួយភាគធំទៅ ហើយដោយសារតែការប្រែប្រួលនៃធម្មជាតិ និងការ-អភិវឌ្ឍរបស់ប្រជាជនទាំងសងខាងខ្សែព្រំដែន ។ ប្រការនេះ គឺជាហេតុដែលនាំឱ្យ

ផែនទី និង ស្ថានភាពដីជាក់ស្ដែង មានលក្ខណៈមិនដូចគ្នា ។ ដូច្នេះ វាជាការចាំបាច់ណាស់ ដែលត្រូវមានការកែសម្រួលសំដៅធានានូវភាពស៊ីគ្នារវាងផែនទី និងស្ថានភាពដីជាក់ស្ដែង ឱ្យទៅជារូបភាពតែមួយ ។ លើសពីនេះទៀត ការដែលមានតែផែនទីតែមួយមុខ មិនអាចធ្វើឱ្យយើងបានដឹងច្បាស់ថា ខ្សែព្រំដែនពិតប្រាកដរបស់ខ្លួននៅត្រឹមណា និងនៅកន្លែងណា នៅលើដីជាក់ស្ដែងនោះទេ ។ មានផែនទីហើយក៏ដោយ ក៏នៅតែជាការចាំបាច់មិនអាចខ្វះបាន ដែលយើងត្រូវមានបង្គោលព្រំដែន និង របងព្រំដីនៅលើដីជាក់ស្ដែង នោះទើបខ្សែព្រំដែននេះ ក្លាយទៅជាព្រំដែនអន្តរជាតិត្រឹមត្រូវ ស្របតាមលក្ខណៈបច្ចេកទេស និងច្បាប់ ដែលអាចងាយស្រួលក្នុងការការពារ និងសម្រាប់ចំណាំរបស់ប្រជាពលរដ្ឋក្នុងការកាន់កាប់ ប្រើប្រាស់ធ្វើអាជីវកម្ម និង បង្កបង្កើនផលដោយគ្មានផលរមាស់ ។

ខ្ញុំមានជំនឿថា ប្រជាពលរដ្ឋកម្ពុជាដ៏ច្រើនលើសលប់ ពិតជាអាចយល់បានពីជម្រៅនៃគោលបំណងរបស់ក្រុមអ្នកនយោបាយដែល ***«ខ្លាចបាត់ទឹកដី តែប្រឆាំងនឹងការធ្វើរបង (បោះបង្គោលព្រំដែន)»*** ឬ ***«ចោទថាអ្នកជិតខាងរំកិលចូលទឹកដីកម្ពុជា តែប្រឆាំងនឹងការធ្វើរបង (ការបោះបង្គោល) ការពារព្រំដែន»*** នេះ ។

ឈរលើមូលដ្ឋានដូចបានបញ្ជាក់ខាងលើនេះ ភាគីទាំងពីរបានចាប់ផ្ដើមធ្វើការជាមួយគ្នានៅក្នុងស្មារតីយោគយល់ និង ប្រកបដោយការទទួលខុសត្រូវខ្ពស់បំផុត រហូតដល់សម្រេចបាននូវសន្ធិសញ្ញាបំពេញបន្ថែមទៅលើសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋ ឆ្នាំ ១៩៨៥ រវាងព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋសង្គមនិយមវៀតណាម ដែលត្រូវបានចុះហត្ថលេខានា ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០០៥ ។ កម្មវត្ថុនៃសន្ធិសញ្ញាបំពេញបន្ថែមនេះ គឺសំដៅកែសម្រួលទិសដើរនៃខ្សែព្រំដែនគោកដើរតាមទន្លេ ឬផ្លូវទឹក ដើម្បីកំណត់ខ្សែព្រំដែនដើរតាមទន្លេ ឬផ្លូវទឹក ស្របតាមគោលការណ៍ និងការអនុវត្តអន្តរ-ជាតិ ពោលគឺ ÷

- ចំពោះកំណាត់ព្រំដែនទឹក ដើរតាមព្រែក- ស្ទឹងដែលមិនអាចធ្វើចរាចរណ៍បាន ខ្សែព្រំដែនត្រូវដើរតាមបន្ទាត់ទ្រូងនៃផ្លូវទឹកនោះ ។

- ចំពោះកំណាត់ព្រំដែនទឹកតាមព្រែក- ស្ទឹងដែលអាចធ្វើចរាចរណ៍បាន ខ្សែព្រំដែនត្រូវដើរតាមបន្ទាត់ទ្រូងនៃជ្រលងទឹកជ្រៅ ។

ត្រង់នេះ យើងគួរធ្វើការកត់សម្គាល់ថា ស្របតាមគំនូសខ្សែព្រំដែនដើរតាមផ្លូវទឹកនៃផែនទីដែលអាណាព្យាបាលបារាំងបានបន្សល់ទុកឱ្យនោះ គឺមិនមានការយកចិត្តទុកដាក់ដល់ការបែងចែកទឹកសម្រាប់ប្រជាពលរដ្ឋនៃភាគីទាំងសងខាង នៅតាមបណ្ដោយព្រំដែនដែលមានព្រែក ឬស្ទឹងនេះទេ ។ បានន័យថា នៅតាមទីតាំងមួយចំនួនដែលមានភាគីណាម្ខាងទទួលបានតែមាត់ច្រាំង ភាគីនោះនឹងមិនអាចប្រើប្រាស់ទឹកបានឡើយ ។ ជារួមករណីនេះ ភាគច្រើនមាននៅខាងកម្ពុជាយើង ។ ខ្ញុំសូមបញ្ជាក់ថា ខ្សែព្រំដែនដើរតាមផ្លូវទឹកនៃព្រំដែនគោករវាងកម្ពុជាវៀតណាមមានប្រវែងសរុបប្រមាណជា ៣៨៣,៥ គីឡូម៉ែត្រ ក្នុងនោះ រដ្ឋបាលអាណាព្យាបាលបារាំងបានគូសដាក់ទឹកនៅខាងកម្ពុជាប្រវែង ១៩១ គីឡូម៉ែត្រ ដែលសុទ្ធសឹងជាតំបន់ព្រៃស្ងាត់ មានប្រជាជនរស់នៅតិចតួច ដូចជា នៅខេត្តរតនគិរី ខេត្តមណ្ឌលគិរី និង ខេត្តក្រចេះ ជាដើម ។ ចំណែកឯខ្សែព្រំដែនដើរតាមផ្លូវទឹក ដែលបារាំងគូសឱ្យទៅខាងភាគីវៀតណាមវិញ មានប្រវែងសរុប ១៩២,៥ គីឡូម៉ែត្រ តែសុទ្ធសឹងជាតំបន់ដែលមានប្រជាជនរស់ច្រើនកុះករ ដូចជា នៅខេត្តកំពង់ចាម, ខេត្តស្វាយរៀង, ខេត្តព្រៃវែង, ខេត្តកណ្ដាល និង ខេត្តតាកែវ ជាដើម ។ ក៏ប៉ុន្តែ តាមរយៈសន្ធិសញ្ញាបំពេញបន្ថែមថ្មីនេះ ភាគីទាំងពីរ បានឯកភាពគ្នាចែកទឹកពាក់កណ្ដាលម្នាក់ ។ ចំណុចនេះ ពិតជាមានសារៈសំខាន់ណាស់ សម្រាប់ប្រជាពលរដ្ឋនៃប្រទេសទាំងសងខាង ពីព្រោះ ក្នុងការអនុវត្តជាក់ស្ដែងទៅថ្ងៃក្រោយ ប្រជាពលរដ្ឋកម្ពុជាដែលរស់នៅតាមបណ្ដោយខ្សែព្រំដែនទឹក នឹងមានសិទ្ធិប្រើប្រាស់ទឹកទន្លេ ព្រែក ស្ទឹងទាំងនោះ ដោយមិនចាំបាច់សុំការអនុញ្ញាតពីភាគីម្ខាងទៀតនោះទេ ។

ក្រៅពីនេះ នៅក្នុងសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ ២០០៥ នេះ ភាគី ទាំងពីរបានឯកភាពគ្នាកែសម្រួលខ្សែព្រំដែន ៦ កន្លែង ដោយយកតាមគោលការណ៍ធំៗ ៤ ជាមូលដ្ឋានគឺ÷

ទី១- មូលដ្ឋានច្បាប់ដែលរដ្ឋបាលអាណានិគមបានប្រើប្រាស់

ទី២- ការគ្រប់គ្រងពិតប្រាកដ និង ការកាន់កាប់ជាក់ស្ដែងរបស់ប្រជាជនជាច្រើនជំនាន់

ទី៣- ស្ថានភាពភូមិសាស្ត្រ និង ឋានលេខាស្របទៅនឹងបណ្តាគោលការណ៍ច្បាប់ និង

ទី៤- ការអនុវត្តអន្តរជាតិ សម្រាប់អនុវត្តនៅក្នុងការកំណត់ទិសដើរនៃខ្សែព្រំដែនទៅតាមសណ្ឋានដី ដូចជា ខ្សែបែងចែកទឹក ខ្សែជួរកំពូលភ្នំ ខ្សែរយៈកំពស់ ។ល។

ក្រៅពីនេះ ក៏នៅមានចំណុចមិនទាន់ឯកភាពមួយចំនួនផងដែរ នោះគឺកំណាត់ព្រំដែននៅតំបន់ជាប់នឹងឃុំដាក់ដាង ស្រុកអូររាំង ខេត្តមណ្ឌលគិរី (ខាងកម្ពុជា) និង ឃុំខ្វាងជិក ស្រុកដាក់ឡឹប ខេត្តដាក់ណុង (ខាងវៀតណាម) ដែលមានផ្ទៃក្រឡាដីប្រមាណជា ៥០ គីឡូ ម៉ែត្រក្រឡា ហើយភាគីទាំងពីរបានឯកភាពគ្នាបន្តការពិភាក្សា ។ មូលហេតុដែលមិនទាន់មានការឯកភាពគ្នានេះគឺ ខាងភាគីកម្ពុជាទាមទារយកខ្សែព្រំដែននៅកំណាត់នេះ តាមសេចក្តីសម្រេចរបស់អគ្គទេសាភិបាលបារាំង ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩១៤ ដែលបានបញ្ជាក់ថា «ខ្សែព្រំដែននៅតំបន់នេះ ដើរតាមព្រែកដាក់ហ៊្វិតរហូតដល់ប្រភពនៃព្រែកនោះ» ។ ឯខាងភាគីវៀតណាមទាមទារយកខ្សែព្រំដែននៅកំណាត់នេះ ដើរតាមព្រែកដាក់ដាង តាមផែនទីរបស់ក្រុមភូមិសាស្ត្រឥណ្ឌូចិន SGI ខ្នាត ១/១០០ ០០០ និង តាមការកាន់កាប់ជាក់ស្តែងរបស់ប្រជាជនគេដែលមានជាយូរមកហើយ ។

បន្ថែមលើនេះ នៅក្នុងសន្ធិសញ្ញាបំពេញបន្ថែមនេះ ភាគីទាំងពីរក៏បានឯកភាពលើចំណុចសំខាន់មួយចំនួនទៀត រួមមាន ÷

ទីមួយ- ធ្វើការគូសចម្លងឡើងវិញនូវខ្សែព្រំដែន ពីផែនទីបោន (Bonne) ខ្នាត ១/១០០ ០០០ របស់ក្រុមភូមិសាស្ត្រឥណ្ឌូចិនអមសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋឆ្នាំ ១៩៨៥ មកលើផែនទីUTM ខ្នាត ១/៥០ ០០០ អមសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋ ឆ្នាំ ១៩៨៥ ។ ចំណុចនេះ មានសារៈសំខាន់ណាស់ ។ វាមានន័យច្បាស់ថា ភាគីទាំងពីរឯកភាពគ្នាធ្វើសវនកម្ម (Audit) ខ្សែព្រំដែនឆ្នាំ ១៩៨៥ ទូទាំងខ្សែព្រំដែនទាំងមូលឡើងវិញ ដើម្បីឱ្យក្រុមបច្ចេកទេសចម្រុះទាំងពីរយកទៅអនុវត្តន៍នៅលើដីជាក់ស្តែង ។

ទីពីរ- ចំពោះបណ្ដាតំបន់ដែលភាគីទាំងពីរមិនទាន់ឯកភាពគ្នា ទៅលើលទ្ធផលនៃការធ្វើសវនកម្ម ភាគីទាំងពីរនឹងយកផែនទីបោន(Bonne) ខ្នាត ១/១០០ ០០០ ជាមូលដ្ឋាន ។

ទីបី- នៅពេលការងារខណ្ឌសីមា និង បោះបង្គោលព្រំដែន មិនទាន់ត្រូវបានបញ្ចប់ទេនោះ ការគ្រប់គ្រងខ្សែបន្ទាត់ព្រំដែន នឹងត្រូវបន្តអនុវត្តតាមសេចក្ដីប្រកាសព័ត៌មានរួមចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ១៩៩៥ (សូមអានសេចក្ដីដកស្រង់ខ្លឹមសារពីសេចក្ដីប្រកាសព័ត៌មាននេះ ក្នុងឧបសម្ព័ន្ធទី ៣) ។

ទីបួន- ភាគីទាំងពីរនឹងផលិតផែនទីព្រំដែនរដ្ឋរវាងព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋសង្គមនិយមវៀតណាម ។ ផែនទីព្រំដែននេះ នឹងប្ដូរជំនួសពីផែនទីបោន (Bonne) ខ្នាត ១/១០០ ០០០ ចំនួន ២៦ ផ្ទាំង និង ផែនទី UTM ខ្នាត ១/៥០ ០០០ ចំនួន ៤០ ផ្ទាំង អមសន្ធិសញ្ញាកំណត់ព្រំដែនឆ្នាំ ១៩៨៥ និង ប្លង់ទាំង ៤ អមសន្ធិ-សញ្ញាបំពេញបន្ថែម ។ គួរគួសបញ្ជាក់បន្ថែមទៀតថា ផែនទីនេះនឹងផ្អែកលើថានលេខាព្រំដែនថ្មីមួយ ដែលមានខ្នាត ១/២៥ ០០០ និងមានបង្ហាញទីតាំងបង្គោលព្រំដែន និងខ្សែខណ្ឌសីមារវាងប្រទេសទាំងពីរ ដើម្បីយកទៅតម្កល់ទៅអង្គការសហប្រជាជាតិ និងទុកជាផែនទីផ្លូវការ និង ជាអចិន្ត្រៃយ៍តរៀងទៅ ។

ជារួម សន្ធិសញ្ញាបំពេញបន្ថែមនេះ ពិតជាមានអត្ថប្រយោជន៍ជាប្រវត្តិសាស្ត្រសម្រាប់ប្រទេសកម្ពុជា ក្នុងការកសាងព្រំដែនអចិន្ត្រៃយ៍ជាមួយនឹងប្រទេសវៀតណាម ។ សន្ធិសញ្ញាបំពេញបន្ថែមនេះ បានជួយជួសជុលកែលម្អ និង បំពេញបន្ថែម ទាំងខាងគោលការណ៍ច្បាប់ ទាំងខាងបច្ចេកទេស ទៅលើចំណុចខ្វះខាតទាំងឡាយនៃសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋឆ្នាំ ១៩៨៥ ។ ក្នុងន័យនេះ សន្ធិសញ្ញាបំពេញបន្ថែមនេះ នឹងនាំមកជូនភាគីទាំងសងខាងនូវទំនាក់ទំនងជាអ្នកជិតខាងកាន់តែល្អប្រសើរ សុខសន្តិភាព និង ភាពរីកចម្រើនរុងរឿង ទាំង ខាងសង្គមកិច្ច សេដ្ឋកិច្ច ពាណិជ្ជកម្ម កាវិនិយោគ និង ការផ្លាស់ប្ដូរទេសចរណ៍ ។

សំខាន់ជាងនេះទៀត សន្ធិសញ្ញានេះបានបញ្ជាក់យ៉ាងច្បាស់សារជាថ្មី អំពីការ-ជ្រើសរើសរបស់កម្ពុជា នូវគោលការណ៍ច្បាប់អន្តរជាតិ ដែលហៅថា ***«គោលការណ៍ខ្សែ***

***ព្រំដែនមិនកែប្រែ»*** (Uti Possidetis) នៅពេលដែលកម្ពុជាបានឯករាជ្យ មកបន្តអនុវត្ត នៅក្នុងការរកដំណោះស្រាយបញ្ហាព្រំដែនកម្ពុជាជាមួយនឹងប្រទេសជិតខាង ។ ដូច្នេះ សន្ធិសញ្ញាបំពេញបន្ថែមនេះ បន្តកិច្ចការដែលរាជរដ្ឋាភិបាលសម័យសង្គមរាស្ត្រនិយម បានធ្វើកន្លងមក ដើម្បីនាំទៅដល់ការបញ្ចប់បានទាំងស្រុងនូវខ្សែព្រំដែនមួយច្បាស់-លាស់ ទាំងលើផែនទី ទាំងលើដីជាក់ស្តែង ដើម្បីធានាបាននូវបូរណភាពទឹកដីកម្ពុជា និង ដើម្បីធ្វើឱ្យប្រជាជនកម្ពុជាលែងមានការស្រពិចស្រពិល ស្គាល់ច្បាស់នូវព្រំដែនពិតប្រាកដរបស់ខ្លួន តាមរយៈបង្គោលព្រំដែនដែលស្តែងឡើងនៅលើដីជាក់ស្តែង ងាយស្រួលក្នុងការចំណាំ ការគ្រប់គ្រង ការការពារ និង ការអភិវឌ្ឍនៅតំបន់ព្រំដែន ។

និយាយជារួម តាំងពីចាប់ផ្តើមកំណើតរបស់ខ្លួនមក រាជរដ្ឋាភិបាលនៃរាជាណាចក្រកម្ពុជាទី ២ នេះ បានប្រកាន់យ៉ាងខ្ជាប់ខ្ជួន និង ប្រកបដោយសង្គតិភាពនូវគោល-ការណ៍ជាយុទ្ធសាស្ត្រមួយចំនួន នៅក្នុងការខិតខំដោះស្រាយបញ្ហាព្រំដែនជាមួយនឹងប្រទេសជិតខាង រួមមាន ៖

ទីមួយ- ធានាការពារឱ្យបានដាច់ខាតនូវអធិបតេយ្យភាព និង បូរណភាពទឹកដី ដោយឈរលើគោលការណ៍ជាមូលដ្ឋាននៃ ***«ខ្សែព្រំដែនមិនកែប្រែនៅពេលដែលកម្ពុជាបានឯករាជ្យ»*** ដូចមានកំណត់ក្នុងមាត្រា ២ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និង ស្របតាមចំណុចII មាត្រាទី ១ ឃ នៃកិច្ចព្រមព្រៀងប៉ារីស ចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ១៩៩១ ក៏ដូចជាស្របទៅនឹងព្រះរាជតម្រិះដ៏ភ្លឺស្វាងបំផុតរបស់ព្រះមហាវីរក្សត្រ សម្តេចព្រះ **នរោត្តម សីហនុ** ព្រះវររាជបិតាជាតិខ្មែរ ដែលព្រះអង្គបានយកផែនទីកម្ពុជា- វៀតណាម ទាំងព្រំដែនគោក ទាំងព្រំដែនសមុទ្រ ទៅតម្កល់នៅអង្គការសហ-ប្រជាជាតិ នាឆ្នាំ ១៩៦៤ ។

ទីពីរ- ដោយឈរលើមូលដ្ឋាននៃគោលការណ៍ទីមួយខាងលើ ធានាឱ្យកម្ពុជាមានខ្សែព្រំដែនមួយច្បាស់លាស់ ដោយប្រែក្លាយព្រំដែនពាក់កណ្តាលរដ្ឋបាល និង ពាក់-កណ្តាលអន្តរជាតិឱ្យទៅជាព្រំដែនអន្តរជាតិពិតប្រាកដ ព្រមជាមួយនេះដែរ ប្រែក្លាយខ្សែព្រំដែនដែលមានតែនៅលើផែនទី ឱ្យទៅជាបង្គោលព្រំដែននៅលើដីជាក់ស្តែង ហើយខ្សែព្រំដែននេះទៀតសោត នៅពេលណាដែលភាគីទាំងពីរបញ្ចប់ការងារបោះ

បង្គោល និង ខណ្ឌសីមាព្រំដែនរួចរាល់ហើយ គឺត្រូវស្របគ្នាទៅនឹងការកាន់កាប់ជាក់-ស្តែងរបស់ប្រជាពលរដ្ឋ ដែលរស់នៅតាមបណ្តោយព្រំដែនទាំងសងខាង ។

ទីបី- អនុវត្តការងារនៅក្នុងចំណុចទីពីរខាងលើ ក្នុងស្មារតីសន្តិភាព មិត្តភាព សហប្រតិបត្តិការ និង ការសម្រុះសម្រួល ក្នុងឋានៈជារដ្ឋអធិបតេយ្យដែលជាដៃគូស្មើ-ភាព និង ស្មើសិទ្ធិជាមួយគ្នា ដោយឈរលើមូលដ្ឋាននៃច្បាប់ជាតិ និង អន្តរជាតិ ។

ទីបួន- កសាងព្រំដែនកម្ពុជាជាមួយប្រទេសជិតខាង ឱ្យទៅជាព្រំដែនសន្តិភាព មិត្តភាព សហប្រតិបត្តិការ និង ការអភិវឌ្ឍ ដែលនឹងផ្តល់ផលប្រយោជន៍ដ៏ពិតប្រាកដ ដល់ប្រទេស និង ប្រជាជន ដែលចូលរួមពាក់ព័ន្ធទាំងអស់ ពិសេសគឺប្រជាពលរដ្ឋដែល រស់នៅតាមបណ្តោយព្រំដែន ។

គឺជាប្រការដ៏គួរឱ្យសោកស្តាយណាស់ ដែលកិច្ចខិតខំប្រឹងប្រែងដ៏ខ្លាំងក្លា ប្រកប ដោយឆន្ទៈមោះមុតឥតរាថយរបស់រាជរដ្ឋាភិបាល សំដៅដោះស្រាយបញ្ហាព្រំដែនដែល ជាមរតកប្រវត្តិសាស្ត្រដ៏លំបាកស្មុគស្មាញ នៅក្នុងក្របខ័ណ្ឌនៃគោលការណ៍ជាយុទ្ធ-សាស្ត្រ ដូចបានគូសបញ្ជាក់ពីខាងលើនេះ មិនត្រូវបានមើលឃើញ ឬក៏ត្រូវបានធ្វើជា មើលមិនឃើញ ដោយមជ្ឈដ្ឋានមួយចំនួនទៅវិញ ។ មិនត្រឹមតែប៉ុណ្ណោះ កិច្ចការដ៏ រសើប និង មានសារសំខាន់ជាអាយុជីវិតរបស់ប្រទេសជាតិនេះ ត្រូវបានគេយកមកធ្វើ ជាកម្មវត្ថុនៃការធ្វើអាជីវកម្មជាប់ជាប្រចាំ ប្រកបដោយគ្រោះថ្នាក់ ក្នុងទិសដៅកេងយក ផលចំណេញខាងនយោបាយ សម្រាប់បម្រើឱ្យផលប្រយោជន៍បុគ្គល ឬ ក្រុមមនុស្ស មួយចំនួនតូចថែមទៀតផង ។

ដូចខ្ញុំបានលើកឡើងពីខាងដើមជារឿយៗ រាជរដ្ឋាភិបាលតែងបានទទួលរងនូវ ការចោទប្រកាន់ថា បានធ្វើការចរចាបញ្ហាព្រំដែន ឬ បានធ្វើការបោះបង្គោលព្រំដែន ដោយមិនមានតម្លាភាព និង គណនេយ្យភាព មិនត្រឹមត្រូវច្បាស់លាស់ មិនអនុញ្ញាតឱ្យ មានឱ្យគណបក្សប្រឆាំង ឬអង្គការមិនមែនរដ្ឋាភិបាល ឬអ្នកសង្កេតការណ៍បរទេសចូល រួម ។ល។

ខ្ញុំមានជំនឿថា អ្នកដែលលើកឡើងនូវមតិប្លែកៗទាំងនេះ ពិតជាដឹងច្បាស់ណាស់ ថា ការចរចាបញ្ហាព្រំដែន គឺជាកិច្ចការមួយដែលមានលក្ខណៈរសើបបំផុត ហើយវាគឺជា

សមត្ថកិច្ចការងាររវាងរដ្ឋអធិបតេយ្យមួយជាមួយនឹងរដ្ឋអធិបតេយ្យមួយទៀត ដែលក្នុងនេះ រដ្ឋាភិបាលនៃប្រទេសនីមួយៗ គឺជាអ្នកទទួលខុសត្រូវ ។ ការចរចានេះ មិនអាចយកមកបើកកកាយជាសាធារណៈ មុននឹងសម្រេចបានជាលទ្ធផលណាមួយនោះទេ ។ បើពុំនោះសោត ផលប្រយោជន៍នៃប្រទេសជាតិអាចនឹងត្រូវបាត់បង់ ។ ផ្ទុយទៅវិញ នៅពេលដែលសម្រេចបានជាលទ្ធផលការងារ ដូចជា ការសម្រេចបាននូវកិច្ចព្រមព្រៀង ឬការបោះបង្គោលកំណត់ព្រំដែនរួចហើយនោះ រាជរដ្ឋាភិបាលមិនដែលបានលាក់បិទបាំងនូវសមិទ្ធផលការងារ ដែលមានសារៈសំខាន់ជាអាយុជីវិត និង ជាមោទនភាពរបស់ជាតិនោះឡើយ ។ យើងតែងតែបានផ្តល់របាយការណ៍ដល់រដ្ឋសភា ដែលជាស្ថាប័នតំណាងឱ្យឆន្ទៈប្រជាជនដ៏ពិតប្រាកដ និង ចាត់ចែងធ្វើការផ្សព្វផ្សាយយ៉ាងទូលំទូលាយ ជូនដល់សាធារណជនគ្រប់ស្រទាប់ជាន់ថ្នាក់ ឱ្យបានជ្រួតជ្រាបអំពីសមិទ្ធផលដ៏មានសារសំខាន់ និង គួរជាទីមោទនៈទាំងនេះ រហូតដល់រៀបចំឱ្យទៅទីកន្លែងសម្រាប់ទេសចរមកទស្សនាទៀតផង ។ លើសពីនេះ បង្គោលព្រំដែននៅក្នុងសម័យបច្ចេកវិទ្យាទំនើបនាពេលបច្ចុប្បន្ននេះ ត្រូវបានរៀបចំ ដោយរឹងមាំ និង ងាយមើលឃើញ រហូតដល់មានបង្កប់មីក្រូឈីប(Microchip) ដើម្បីអាចងាយរកឃើញពីផ្កាយរណបផងដែរ ។

លើសពីនេះទៀត ខ្ញុំយល់ថា ការចោទប្រកាន់ដោយគ្មានភស្តុតាងត្រឹមត្រូវថា ប្រទេសជិតខាងរបស់កម្ពុជាបានលួចរំកិលបង្គោលព្រំដែន ឬ រំលោភចូលមកយកដីកម្ពុជា រាប់រយ រាប់ពាន់គីឡូម៉ែត្រក្រឡានោះ វាគឺជាការញុះញង់បំភាន់ឱ្យមានការយល់ច្រឡំ ប្រកបដោយគ្រោះថ្នាក់ និង ដោយគ្មានការទទួលខុសត្រូវ ។ ប្រការនេះ អាចនឹងដុតកម្តៅឱ្យពុះកញ្ជ្រោលឡើង នូវស្មារតីជាតិនិយមជ្រុល បង្ករឱ្យមានអរិភាពជាតិសាសន៍ ធ្វើឱ្យខូចខាតយ៉ាងធ្ងន់ធ្ងរដល់ទំនាក់អ្នកជិតខាងល្អ មិត្តភាព និង កិច្ចសហប្រតិបត្តិការរវាងប្រទេស និង ប្រជាជនទាំងសងខាង ។ លើសពីនេះទៀត ទង្វើបែបនេះថែមទាំងអាចបង្ករឱ្យមានអស្ថិរភាពផ្ទៃក្នុងប្រទេសថែមទៀតផង ។ ក្នុងន័យនេះ ការញុះញង់ប្រជាពលរដ្ឋដែលមានចំណេះដឹងតិចតួច ឱ្យចូលរួមបង្កើតបញ្ហាជាមួយនឹងខ្លួន ដូចជា ការដើរដកបង្គោលតម្រុយព្រំដែនដែលបានកំណត់ហើយ យកទៅបោះចោល

ជាដើម គឺមិនមែនជាទង្វើដែលគួរឱ្យលើកសរសើរនោះទេ ។ ផ្ទុយទៅវិញ អ្នកប្រព្រឹត្តិល្មើស គប្បីត្រូវតែបានទទួលទោសតឹងរឹងស្របទៅតាមបទប្បញ្ញត្តិច្បាប់កំណត់ ។

ម៉្យាងវិញទៀត ដូចខ្ញុំបានលើកឡើងពីខាងដើមហើយដែរថា ការស្នេហាជាតិ និង ការការពារបូរណភាពទឹកដី គឺជាសិទ្ធិ និង កាតព្វកិច្ចរបស់ពលរដ្ឋកម្ពុជាគ្រប់រូប ។ ក្នុងរយៈកាលកន្លងមក កងម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និង ប្រជាជនកម្ពុជាដ៏ច្រើនកុះករ ពិសេសបងប្អូនប្រជាជនដែលរស់នៅតាមបណ្តោយព្រំដែន នៅគ្រប់ទិសទី បានចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចការនេះ ទាំងដោយត្រង់ និង ដោយប្រយោល ។ រាជរដ្ឋាភិបាលក៏បានបង្វែរទុនវិនិយោគដ៏ច្រើនសន្ធឹកសន្ធាប់ផងដែរ ទៅកាន់តំបន់ជាយដែនសំខាន់ៗ ដើម្បីកសាងនូវប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង ផ្តល់មធ្យោបាយសម្រួលសមស្រប សំដៅធានាឱ្យកងកម្លាំង និង ប្រជាជនយើង អាចបំពេញការងារ រស់នៅ និង ធ្វើការ-ងារអភិវឌ្ឍភូមិឋានរបស់ខ្លួន ។ ការបោះទីលំនៅជាប់លាប់ និង ការអភិវឌ្ឍភូមិឋាននៅតាមតំបន់ព្រំដែនទាំងអស់នោះ គឺជារបងការពារបូរណភាពទឹកដីមួយយ៉ាងសំខាន់ ។ ដូច្នេះ ការចោទប្រកាន់ថា មានការអនុញ្ញាតឱ្យប្រទេសជិតខាងចូលមករំលោភយកទឹកដីដោយស្រួលៗ អស់រាប់រយ រាប់ពាន់គីឡូម៉ែត្រក្រឡានេះ គឺមានន័យស្មើនឹងការមើលស្រាលចំពោះកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ដែលទទួលភារកិច្ចការពារខ្សែបន្ទាត់ព្រំដែនរបស់ប្រទេសជាតិ និងប្រជាជនកម្ពុជារាប់ម៉ឺនគ្រួសារដែលរស់នៅតាមបណ្តោយព្រំដែនទាំងនោះផងដែរ ។

ដូចដែលយើងទាំងអស់គ្នាបានដឹងស្រាប់ថា ដើម្បីសម្រេចបាននូវព្រំដែនមួយប្រកបដោយសន្តិភាព មិត្តភាព កិច្ចសហប្រតិបត្តិការ និង ការអភិវឌ្ឍ ប្រទេសនីមួយៗមិនអាចកសាងខ្សែព្រំដែនតែឯកឯងបាននោះទេ ។ វាជាការចាំបាច់ណាស់ដែលប្រទេសសាមីទាំងសងខាងខិតខំរកដំណោះស្រាយរួមគ្នា ដោយគោរពគ្នាទៅវិញទៅមក ក្នុងសុឆន្ទៈចង់ដោះស្រាយដោយពិតប្រាកដ ហើយឈរលើស្មារតីស្មោះត្រង់ មិនកេងចំណេញពីគ្នា ។ ក្នុងន័យនេះ យើងគួរតែផ្តល់ការវាយតម្លៃសមស្របជូនដល់រដ្ឋាភិបាលវៀតណាម ដែលបានសំដែងនូវសុឆន្ទៈ និងការគោរពចំពោះឯករាជ្យ និងអធិបតេយ្យ-ភាពជាតិរបស់កម្ពុជា ហើយធ្វើការចរចាដោយស្មោះត្រង់ជាមួយនឹងរាជរដ្ឋាភិបាល

សំដៅស្វែងរកដំណោះស្រាយលើបញ្ហាព្រំដែនដ៏ស្មុគស្មាញនេះ ដើម្បីផលប្រយោជន៍របស់ប្រទេស និង ប្រជាជនទាំងសងខាង ។

## II- អំពីព្រំដែនសមុទ្រ

នៅឆ្នាំ ១៩៦៤ កម្ពុជាបានយកផែនទីព្រំដែនសមុទ្រខ្នាត ១/ ៣០០ ០០០ បោះពុម្ពដោយក្រុមភូមិសាស្ត្រកម្ពុជា ដែលបានយកខ្សែប្រេវីយ៉េ(Brévié) ឆ្នាំ ១៩៣៩ កំណត់ជាខ្សែព្រំដែនសមុទ្ររវាងកម្ពុជា និង វៀតណាម ទៅតម្កល់ទុកនៅអង្គការសហប្រជាជាតិ និង បានស្នើសុំឱ្យប្រទេសសាមី និង អន្តរជាតិ ទទួលស្គាល់ខ្សែព្រំដែននេះថា ជាខ្សែព្រំដែនសមុទ្ររវាងប្រទេសទាំងពីរកម្ពុជា- វៀតណាម ។ កម្ពុជានាពេលនោះ ក៏ទទួលបានការគាំទ្រពីប្រទេសសាមី និង ពីអន្តរជាតិមួយចំនួន ដោយទទួលស្គាល់ថា ខ្សែប្រេវីយ៉េជាខ្សែព្រំដែនសមុទ្ររវាងកម្ពុជា និង វៀតណាម ( សូមមើលផែនទីខ្សែប្រេវីយ៉េ ក្នុងឧបសម្ព័នទី ៤) ។

តែនៅឆ្នាំ ១៩៧០ រដ្ឋាភិបាលធីវគីបានអនុម័តច្បាប់ស្តីពីប្រេងកាតដែលបញ្ជាក់ពីតំបន់ខ្ពង់រាបបាតសមុទ្ររបស់វៀតណាម ហើយចាប់ផ្តើមធ្វើការកំណត់តំបន់ខ្ពង់រាបបាតសមុទ្រនេះ នៅឆ្នាំ ១៩៧១ ។ ផ្អែកលើច្បាប់នេះ នៅឆ្នាំ ១៩៧១ រដ្ឋាភិបាលធីវគីបានគូសខ្សែព្រំដែនសមុទ្ររបស់ខ្លួនមួយទៀត ដែលព័ទ្ធយកទាំងកោះវៃរបស់កម្ពុជា ( សូមមើលផែនទីខ្សែ ១៩៧១ ក្នុងឧបសម្ព័ន្ធទី ៥) ។ នៅឆ្នាំ ១៩៧២ របបសាធារណរដ្ឋខ្មែរបានគូសខ្សែព្រំដែនសមុទ្រមួយទៀតផ្សេងពីខ្សែប្រេវីយ៉េ ដោយឈរលើគោលការណ៍សមចម្ងាយ (Equidistance) ដែលជាខ្សែមួយមានចម្ងាយស្មើគ្នាពីឆ្នេរសមុទ្រ ឬ ពីកោះ ដោយនៅផ្នែកខាងលិចចាត់ទុកកោះគត់ ជាកោះព្រំដែន ។ គេធ្វើនេះ គឺដោយយោងតាមសន្ធិសញ្ញាបារាំង- សៀម ឆ្នាំ ១៩០៧ ដែលចាត់ទុកថា នៅផ្នែកខាងកើតកោះត្រល់ និង កោះថូជូ គឺជារបស់ខ្មែរ ( សូមមើលផែនទីខ្សែឆ្នាំ ១៩៧២ ក្នុងឧបសម្ព័ន្ធទី ៦) ។

ការវិវត្តិបន្តមកទៀត គឺមានការពាក់ព័ន្ធជាសំខាន់ទៅនឹងកិច្ចព្រមព្រៀងស្តីពីតំបន់ទឹកប្រវត្តិសាស្ត្រឆ្នាំ ១៩៨២ ។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតធ្វើការពន្យល់ដោយសង្ខេបអំពីកិច្ចព្រមព្រៀងនេះ ។

កិច្ចព្រមព្រៀងតំបន់ទឹកប្រវត្តិសាស្ត្រឆ្នាំ ១៩៨២ ពុំទាន់បានកំណត់ព្រំដែនសមុទ្ររវាងប្រទេសទាំងពីរនៅឡើយទេ ទោះជានៅក្នុងឆ្នាំ ១៩៦៤ កម្ពុជាបានយកផែនទី ដែលមានខ្សែប្រេវីយ៉េ ឆ្នាំ ១៩៣៩ ទៅឱ្យអន្តរជាតិទទួលស្គាល់ និងបានដាក់តម្កល់នៅអង្គការសហប្រជាជាតិហើយក៏ដោយ ។ កិច្ចព្រមព្រៀងឆ្នាំ ១៩៨២ បានទុកចំហអំពីភារកិច្ចលើការកំណត់ព្រំដែនសមុទ្រឱ្យរដ្ឋាភិបាលនៃប្រទេសទាំងពីរ ***«ចរចាគ្នាដើម្បីកំណត់ព្រំប្រទល់សមុទ្រក្នុងតំបន់ទឹកប្រវត្តិសាស្ត្រ»*** នេះ ។ កម្ពុជានាពេលនោះ មានជម្រើស ៣ ក្នុងការជ្រើសរើសយកខ្សែព្រំដែនសមុទ្ររវាងកម្ពុជា និង វៀតណាម គឺ ÷

ទី១- ខ្សែប្រេវីយ៉េ ឆ្នាំ ១៩៣៩

ទី២- ខ្សែសាធារណរដ្ឋខ្មែរឆ្នាំ ១៩៧២ ពោលគឺខ្សែសមចម្ងាយ (Equidistance) ឬ

ទី៣- ការចរចាជាមួយវៀតណាម ដើម្បីកំណត់រកចំណុចប្រសព្វសូន្យក្នុងតំបន់ទឹកប្រវត្តិសាស្ត្រ ឆ្នាំ ១៩៨២ នៅលើខ្សែបន្ទាត់ដែលភ្ជាប់កោះថូជូ និង កោះវៃ ថាជាខ្សែព្រំដែនសមុទ្ររវាងកម្ពុជា និង វៀតណាម ។

ភាគីទាំងពីរកម្ពុជា- វៀតណាម បានទទួលស្គាល់ជាផ្លូវការនូវការបែងចែកអធិបតេយ្យភាពលើកោះក្នុងឈូងសមុទ្រសៀម តាមរយៈការបែងចែកខ្សែប្រេវីយ៉េឆ្នាំ ១៩៣៩ និង បានឯកភាពពិភាក្សាគ្នាដើម្បីកំណត់ចំណុចប្រសព្វសូន្យ ដែលជាចំណុចបែងចែកព្រំដែនសមុទ្ររវាងប្រទេសទាំងពីរនៅក្នុងតំបន់ទឹកប្រវត្តិសាស្ត្រ ក៏ដូចជាក្នុងតំបន់ខ្ពង់រាបបាតសមុទ្រ ។ តែការចរចាដើម្បីកំណត់ចំណុចប្រសព្វសូន្យ រហូតមកដល់ពេលនេះនៅពុំទាន់ឈានដល់ការឯកភាពគ្នានៅឡើយទេ ដោយកម្ពុជាទាមទារយកខ្សែប្រេវីយ៉េ ឆ្នាំ ១៩៣៩ ជាខ្សែព្រំដែនសមុទ្ររវាងប្រទេសទាំងពីរ តែភាគីវៀតណាមទាមទារយកខ្សែសមចម្ងាយ (Ligne d équidistance) ដោយគេចាត់ទុកថាខ្សែប្រេវីយ៉េ គ្រាន់តែជាខ្សែបែងចែកអធិបតេយ្យភាពលើកោះតែប៉ុណ្ណោះ (សូមមើលផែនទី ក្នុងឧបសម្ព័ន្ធទី ៧) ។

ដូច្នេះ តើកិច្ចព្រមព្រៀងតំបន់ទឹកប្រវត្តិសាស្ត្របានធ្វើឱ្យបាត់បង់ទឹកដី ១០ ០០០ គីឡូម៉ែត្រក្រឡាមែនឬទេ? ចម្លើយ គឺខ្លី និង សាមញ្ញណាស់ថា ឥតមានធ្វើឱ្យបាត់ទេ? ដូចបានជម្រាបជូនពីខាងលើរួចហើយថា កិច្ចព្រមព្រៀងនេះ ពុំទាន់បានកំណត់ព្រំដែនសមុទ្ររវាងប្រទេសទាំងពីរនៅឡើយទេ ។ លើសពីនេះទៀត ភាគីទាំងពីរត្រូវបន្តការ-

ចរចារកចំណុចប្រសព្វសូន្យរវាងកោះវៃ និង កោះថូជូ ដើម្បីកំណត់ខ្សែព្រំដែននៅក្នុងតំបន់ទឹកប្រវត្តិសាស្ត្រ ។

តាមពិត ការចោទប្រកាន់ខាងលើនេះ ធ្វើឡើងដោយយោងទៅលើខ្សែឆ្នាំ ១៩៧២ ដែលត្រូវបានគូសជាឯកតោភាគីដោយរដ្ឋាភិបាលសាធារណៈរដ្ឋខ្មែរ ។ ធាតុពិតគេបានបំភ្លេចចោលនូវផែនទីខ្សែប្រេវីយេ ឆ្នាំ ១៩៣៩ ដែលសម្តេចព្រះ **នរោត្តម សីហនុ** បានយកទៅតម្កល់នៅអង្គការសហប្រជាជាតិ នាឆ្នាំ ១៩៦៤ ហើយបានតស៊ូទាមទារយ៉ាងស្វិតស្វាញសុំឱ្យអន្តរជាតិ និង ប្រទេសសាមី យល់ព្រមទទួលស្គាល់នោះ ។ ដូច្នេះ បើមើលពីសម្បកក្រៅទៅឃើញថា អ្នកចោទប្រកាន់មកលើកិច្ចព្រមព្រៀងតំបន់ទឹកប្រវត្តិ-សាស្ត្រនេះ ហាក់មានបំណងចង់ធ្វើការវាយប្រហារខាងនយោបាយមកលើរដ្ឋាភិបាលនៃអតីតសាធារណរដ្ឋប្រជាមានិតកម្ពុជា ស្ថិតនៅក្រោមការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា ដែលមានរូបខ្ញុំផ្ទាល់ជាហត្ថលេខី ក្នុងនាមជារដ្ឋមន្ត្រីក្រសួងការបរទេស នាពេលនោះ ។ ក៏ប៉ុន្តែ បើពិនិត្យស៊ីជម្រៅផ្ទៃក្នុងទៅឃើញថា ការចោទប្រកាន់នេះ មានគោលដៅវែងឆ្ងាយជាងបំណងវាយប្រហារទៅលើគណបក្សប្រជាជនកម្ពុជា និង លើបុគ្គល **ហ៊ុន សែន** ខ្ញុំផ្ទាល់នេះទៅទៀត ។ គោលបំណងស៊ីជម្រៅរបស់គេ គឺអាចជាការចង់អះអាងអំពីភាពត្រឹមត្រូវនៃការធ្វើរដ្ឋប្រហាររបស់ក្រុមសាធារណរដ្ឋ ដើម្បីផ្តួលរំលំព្រះករុណា សម្តេចព្រះ **នរោត្តម សីហនុ** នៅឆ្នាំ ១៩៧០ ហើយលើកតម្កើងខ្លួនឯងជាវីរជនស្នេហាជាតិខ្ពស់ជាងព្រះវររាជបិតាជាតិខ្មែររបស់យើងពេលនេះទៅទៀត ។

ដើម្បីភាពច្បាស់លាស់បន្ថែមលើការអធិប្បាយខាងលើនេះ ខ្ញុំសូមអនុញ្ញាតធ្វើការបញ្ជាក់បន្តិចអំពីបញ្ហាកោះត្រល់ និង កោះវៃ ។

**ទីមួយ- អំពីកោះត្រល់ :** តើកោះត្រល់លែងជារបស់កម្ពុជាតាំងពីពេលណាមក? ចំពោះសំណួរនេះ ខ្ញុំសូមបញ្ជាក់ដូចតទៅ ÷

ទីមួយ- នៅឆ្នាំ ១៩៣៩ លោក **ប្រេវីយេ** បានដាក់កោះត្រល់ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់វៀតណាម (កូសាំងស៊ីន) ។

ទីពីរ- នៅឆ្នាំ ១៩៤៩ កូសាំងស៊ីន ត្រូវបានបារាំងប្រគល់ទៅឱ្យព្រះចៅបៅដាយ ។

ទីបី- បន្ទាប់មកនៅឆ្នាំ ១៩៦៤ សម្តេចព្រះ **នរោត្តម សីហនុ** ព្រះប្រមុខរដ្ឋ នាពេលនោះ បានយកផែនទីខ្សែប្រេវីយ៉េឆ្នាំ ១៩៣៩ ទៅតម្កល់នៅអង្គការសហប្រជាជាតិ ហើយស្នើសុំឱ្យអន្តរជាតិ និង ប្រទេសសាមីទទួលស្គាល់ថាជាខ្សែព្រំដែនសមុទ្ររវាងកម្ពុជា និង វៀតណាម ។

ចំណុចចុងក្រោយនេះ មានន័យថា កម្ពុជាឈប់ទាមទារយកកោះត្រល់មកវិញហើយ ពីព្រោះវាជាកោះនៅខាងត្បូងខ្សែប្រេវីយ៉េ ។ ជំហរនេះ ព្រះប្រមុខរដ្ឋបានបញ្ជាក់ជាច្រើនដងជាមួយថ្នាក់ដឹកនាំវៀតណាមខាងជើង និង វៀតណាមខាងត្បូងថា ព្រះអង្គមិនទាមទារយកកោះត្រល់មកវិញទេ ។ ត្រង់នេះ ក៏គួរមានការគូសបញ្ជាក់ដែរថា ប្រការនេះ មិនមែនជាកំហុសរបស់ព្រះករុណា សម្តេចព្រះ **នរោត្តម សីហនុ** នោះទេ ពីព្រោះវាជាមរតកដែលអាណាព្យាបាលបារាំងបានបន្សល់ទុកឱ្យ ដូចមានចែងក្នុងចំណុចទីមួយ និង ទីពីរខាងលើ ។ រដ្ឋាភិបាលកម្ពុជាបន្តបន្ទាប់មកទៀត ក៏បានទទួលយកគោលជំហនេះ ដោយគោរពតាមព្រះរាជតំរិះដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ដែលជាវិរជនស្នេហាជាតិដ៏កំពូលផុតគេរបស់កម្ពុជា ។ ដោយឡែកមានតែរដ្ឋាភិបាលនៃសាធារណរដ្ឋខ្មែរមួយប៉ុណ្ណោះ ដែលបដិសេធមិនទទួលយកជំហនេះ ។ ក្រោយមកទៀត ព្រះមហាក្សត្រ ព្រះករុណាព្រះបាទ សម្តេចព្រះ **នរោត្តម សីហនុ** បានបញ្ជាក់ជំហនេះជាថ្មីម្តងទៀត នៅក្នុងព្រះរាជសារផ្ញើរជូនលោក **ផាំ វ៉ាន់ដុង** នាយករដ្ឋមន្ត្រីវៀតណាម ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ១៩៩៩ ។

**ទីពី- អំពីកោះវ៉ៃ:** ដោយយោងលើខ្សែឆ្នាំ ១៩៧១ នៅឆ្នាំ ១៩៧៤ កម្លាំងពួកធីវគីនៃវៀតណាមខាងត្បូង បានប្រកាសកាន់កាប់យកកោះវ៉ៃនេះ ដោយបានដាក់ទ័ពនៅលើកោះ និងបានបញ្ជាកប៉ាល់រកប្រេងរបស់ក្រុមហ៊ុនបារាំងELF ឱ្យចាកចេញក្នុងរយៈពេល ១៥ ថ្ងៃ ។ ក្រុមហ៊ុនបារាំងនេះ ក៏បញ្ឈប់ការរុករកប្រេង ហើយចាកចេញពីតំបន់កោះនេះទៅ ។

បន្ថែមលើនេះទៀត ដូចបានរំលេចឱ្យឃើញពីខាងលើ រហូតមកដល់ពេលនេះ ក៏នៅតែពុំទាន់មានការឯកភាពគ្នានៅឡើយទេ អំពីការកំណត់ព្រំដែនសមុទ្ររវាងប្រទេសទាំងពីរ ដោយកម្ពុជាទាមទារយកខ្សែប្រេវីយ៉េឆ្នាំ ១៩៣៩ ជាខ្សែព្រំដែនសមុទ្ររវាង

ប្រទេសទាំងពីរ តែភាគីវៀតណាមទាមទារយកខ្សែសមចម្ងាយ ដោយគេចាត់ទុកថាខ្សែប្រេវីយេ៉ គ្រាន់តែជាខ្សែបែងចែកអធិបតេយ្យភាពលើកោះតែប៉ុណ្ណោះ ។ ហេតុដូច្នេះហើយ បានជាមានសេចក្តីត្រូវការចាំបាច់ក្នុងការបែងចែកកោះទាំងនោះឱ្យបានច្បាស់-លាស់ ពិសេសគឺកោះវៃនេះឯង ស្របតាមសេចក្តីសម្រេចរបស់លោកប្រេវីយេ៉ និងស្របទៅនឹងគោលការណ៍ខ្សែព្រំដែនមិនកែប្រែ ដែលកម្ពុជាបានប្រកាសទទួលយករហូតមកដើម្បីងាយស្រួលក្នុងការការពារ ការគ្រប់គ្រង និង ការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋនៅតំបន់នោះ ។

យោងលើភាពចាំបាច់នេះ រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាកាលនោះ ក៏បានចរចាជាមួយរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ហើយស្រុះ-ស្រួលគ្នារៀបចំជាកិច្ចព្រមព្រៀងតំបន់ទឹកប្រវត្តិសាស្ត្រឆ្នាំ ១៩៨២ ដោយបានកំណត់យកតំបន់ទឹកប្រវត្តិសាស្ត្រនេះ ម្ខាងពីចំណុចកោះវៃ ដែលជាកោះរបស់កម្ពុជា ហើយតភ្ជាប់ទៅនឹងចំណុចម្ខាងទៀត គឺកោះថូជូ ដែលជាកោះរបស់វៀតណាម ។ ដោយឡែកខ្សែបន្ទាត់ព្រំដែននៅក្នុងតំបន់ទឹកប្រវត្តិសាស្ត្រនេះ គឺមិនទាន់ត្រូវបានកំណត់នៅឡើយទេ ដែលភាគីទាំងពីរត្រូវបន្តចរចាគ្នាតទៅទៀត ដូចបានបញ្ជាក់ពីខាងលើ ។

ដូច្នេះ កិច្ចព្រមព្រៀងស្តីពីតំបន់ទឹកប្រវត្តិសាស្ត្រឆ្នាំ ១៩៨២ នេះ បានកំណត់ឱ្យឃើញច្បាស់ថា កោះវៃស្ថិតនៅក្រោមអធិបតេយ្យភាពរបស់កម្ពុជា ហើយចាប់តាំងពីពេលនោះមក កងកម្លាំងរបស់កម្ពុជាបានបោះទីតាំងឈរជើងនៅលើកោះវៃជាប់រហូតមកដល់ពេលនេះ ។ ហេតុនេះ ខ្ញុំសូមគូសបញ្ជាក់ច្បាស់ជាថ្មីម្តងទៀតថា គោលដៅចម្បងនៃកិច្ចព្រមព្រៀងតំបន់ទឹកប្រវត្តិសាស្ត្រ គឺការកំណត់អធិបតេយ្យភាពរបស់កម្ពុជាលើកោះវៃនេះឯង ។

## III- អំពីសំណួររបស់ឯកឧត្តម សុន ឆ័យ

ខ្ញុំមានជំនឿថា ការអធិប្បាយទាំងអម្បាលមាណពីខាងលើនេះ ពិតជាបានគ្របដណ្តប់ទៅលើសំណួរភាគច្រើនរបស់ឯកឧត្តម **សុន ឆ័យ** រួចហើយ ។ ម៉្យាងទៀត ខ្ញុំក៏ដឹងដែរថា ***«វាពិតជាការលំបាកខ្លាំងណាស់ កាលណាយើងខំនិយាយអំពីបញ្ហាអ្វីមួយប្រាប់ដល់អ្នកត្រចៀកឈ្លើ– តែធ្វើថ្លង់ ឬចង់បង្ហាញអ្វីមួយដល់អ្នកភ្នែកភ្លឺតែធ្វើជាមើល***

***មិនឃើញ»*** នោះ ។ យ៉ាងណាក៏ដោយ ដោយសារឯកឧត្តមលើកសំណួរមកហើយ ខ្ញុំសូមផ្តល់នូវការបំភ្លឺបន្ថែមតាមចំណុចមួយចំនួនដូចតទៅ ÷

**សំណួរទី១- ការធានាបូរណភាពទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជា តាមព្រំដែនកំណត់ក្នុងផែនទី ដូចមានចែងក្នុងមាត្រា ២ នៃ រដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ :**

ជារួម ខ្ញុំយល់ថា នៅក្នុងការអធិប្បាយខាងលើ ខ្ញុំពិតជាបានឆ្លើយនឹងសំណួរនេះសព្វគ្រប់អស់ហើយ ។ នៅពេលនេះ ខ្ញុំគ្រាន់តែចង់គូសបញ្ជាក់បន្ថែមថា ប្រហែលជាដោយសារតែមានទស្សនៈនយោបាយចង្អៀតចង្អល់ខ្លាំងពេក បានជាអ្នកនយោបាយមួយចំនួន គិតថានៅជុំវិញកម្ពុជាពុំមានប្រទេសណាក្រៅពីប្រទេសវៀតណាមនោះទេ ។ ហេតុនេះហើយ តាំងតែពីឆ្នាំ ១៩៩៣ មក គេនាំគ្នាគិតធ្វើ របងផ្ទះតែម្ខាងនៅទិសខាងកើត ។ មាត្រា ២ នៃរដ្ឋធម្មនុញ្ញចែងថា : ***«បូរណភាពទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជា មិនអាចរំលោភបានដាច់ខាត ក្នុងព្រំដែនរបស់ខ្លួនដែលបានកំណត់ក្នុងផែនទីខ្នាត ១/១០០ ០០០ ធ្វើនៅចន្លោះ ឆ្នាំ១៩៣៣-១៩៥៣ ហើយដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិនៅចន្លោះឆ្នាំ ១៩៦៣-១៩៦៩»*** ។ ខ្ញុំសូមធ្វើការកត់សម្គាល់លើចំណុចមួយចំនួនជុំវិញមាត្រានេះ ។

គេគ្រប់គ្នាដឹងច្បាស់ថា ***តាមរយៈការបោះឆ្នោតដែលរៀបចំដោយ UNTAC នៅឆ្នាំ ១៩៩៣*** គណបក្សប្រជាជនកម្ពុជាមិនបានផុសចេញមកជាគណបក្សដែលទទួលបានការគាំទ្រនាំមុខគេ និង មានអាសនៈច្រើនជាងគេនៅក្នុងរដ្ឋសភានោះទេ ។ បន្ថែមលើនេះ អារម្មណ៍របស់អ្នកនយោបាយដែលបានងើបចេញមកពីការបោះឆ្នោតដែលរៀបចំដោយ UNTAC ក្នុងនាមជាអ្នកឈ្នះនាពេលនោះ គឺពោរពេញទៅដោយការសង្ស័យចំពោះគណបក្សប្រជាជនកម្ពុជា ។ គេចេះតែគិតថា គណបក្សប្រជាជនកម្ពុជា ជាអាយ៉ងរបស់វៀតណាម និង ឃុបឃិតជាមួយវៀតណាម ។ល។ ដែលមកទល់ពេលនេះហើយ នៅតែមានអ្នកបន្តគិតយ៉ាងដូច្នេះនៅឡើយ ហើយថែមយកចំណុចនេះ មកដាក់ជាយុទ្ធសាស្រ្តសម្រាប់ការធ្វើអាជីវកម្មកេងចំណេញខាងនយោបាយរបស់ខ្លួនទៀតផង ។ គឺអាចដោយសារហេតុដូច្នេះហើយ បានជាអ្នកតាក់តែងរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ សរសេរមាត្រា ២ នៃរដ្ឋធម្មនុញ្ញនេះ ដោយផ្តោតអារម្មណ៍របស់ខ្លួន សំដៅតែ

លើព្រំដែននៃទិសខាងកើតរបស់ប្រទេសតែប៉ុណ្ណោះ ដោយភ្លេចគិតថា កម្ពុជាមានព្រំ-ដែនទិសខាងលិចជាមួយថៃ និង ទិសខាងជើងជាមួយនឹងឡាវ ។ ប្រការនេះ បានធ្វើឱ្យគេភ្លេចស្ងួនឡូឈឹងអំពីភាពចាំបាច់ក្នុងការបញ្ចូលផែនទីព្រំដែនអន្តរជាតិកម្ពុជា- ថៃ ខ្នាត ១/២០០ ០០០ ទៅក្នុងមាត្រា ២ នេះ នៃរដ្ឋធម្មនុញ្ញ ។

មួយវិញទៀត ការកំណត់ឆ្នាំបោះពុម្ពលើផែនទីនៅចន្លោះឆ្នាំ ១៩៣៣-១៩៥៣ ក៏មិនស្របទៅនឹងការជាក់ស្តែងទេ ព្រោះថា ÷

- ផែនទីកំណត់ព្រំដែន និង បោះបង្គោលព្រំដែនរវាងកម្ពុជា- កូសាំងស៊ីន-អាណ្ណាម មានតាំងពីទសវត្សរ៍ឆ្នាំ ១៨៨០ មកម្ល៉េះ ឈ្មោះថា ផែនទីមណ្ឌលរដ្ឋបាលកូសាំងស៊ីន
- ផែនទីព្រំដែនកម្ពុជា- ថៃ កំណត់ដោយអនុសញ្ញា និង សន្ធិសញ្ញាបារាំង-សៀម ឆ្នាំ ១៩០៤ និង ឆ្នាំ ១៩០៧ មាន ខ្នាត ១/២០០ ០០០ បោះពុម្ពក្នុងឆ្នាំ ១៩០៧ ដល់១៩០៩ ។

ដូចគ្នានោះដែរ ការកំណត់ខ្នាតផែនទីត្រឹមខ្នាត ១/១០០ ០០០ ជាការខ្វះខាតមួយដ៏មានគ្រោះថ្នាក់ដល់ប្រទេសជាតិ ពីព្រោះ ផែនទីព្រំដែនជាមួយសៀម ពុំមែនមានខ្នាត ១/១០០ ០០០ ទេ តែជាផែនទីដែលធ្វើឡើងបន្ទាប់ពីអនុសញ្ញា និង សន្ធិសញ្ញាបារាំង-សៀម ឆ្នាំ ១៩០៤ និងឆ្នាំ ១៩០៧ ដែលមានខ្នាត ១/២០០ ០០០ ហើយមាន ៧ តំបន់ (៧ សន្លឹក) ។ គឺផែនទីនេះហើយ ដែលព្រះប្រមុខរដ្ឋ សម្តេចព្រះ **នរោត្តម សីហនុ** បានយកទៅតម្កល់នៅអង្គការសហប្រជាជាតិ នៅឆ្នាំ ១៩៦៤ ហើយគឺផែនទីនេះដែរដែលកម្ពុជាយើងយកមកប្រើសព្វថ្ងៃនៅតុលាការយុត្តធម៌អន្តរជាតិក្រុងឡាអេ ក្នុងរឿងក្តីក្តាំជាមួយថៃ សុំឱ្យតុលាការធ្វើការបកស្រាយសាលក្រម ឆ្នាំ ១៩៦២ នោះ ។ ដូច្នេះខ្ញុំយល់ថា យើងគួរតែខិតខំធ្វើការដើម្បីលុបបំបាត់ភាពចន្លោះប្រហោងនេះ ។ ត្រង់នេះខ្ញុំស្នើសូមឱ្យជនរួមជាតិទាំងអស់ មេត្តាយោគយល់ដល់ខ្ញុំ ដែលលើកយកបញ្ហានេះមកបើកកកាយជាសាធារណៈ ពីព្រោះអ្នកដែលបានលើកសំណួរនេះឡើងមក គឺជាអ្នកបង្ខំឱ្យខ្ញុំនិយាយ ។

យ៉ាងណាក៏ដោយ ក្នុងការបំពេញការងាររបស់ខ្លួន រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់គិតគូរដល់របងជុំវិញផ្ទះ ដោយយើងបានដាក់ចេញនូវក្របខ័ណ្ឌយុទ្ធសាស្ត្ររួមសម្រាប់ដោះស្រាយបញ្ហាព្រំដែនជាមួយប្រទេសជិតខាងទាំងអស់ ហើយប្រឹងប្រែងអនុវត្តគោលនយោបាយជាយុទ្ធសាស្ត្រនេះ ឱ្យសម្រេចបានផ្លែផ្កាល្អប្រសើរមួយចំនួន ។ ក៏ប៉ុន្តែ ដោយសារតែផលប្រយោជន៍នយោបាយផ្ទាល់ខ្លួនលើកនេះ ក៏ដូចជាលើកមុនៗដែរ ឯកឧត្តម **សុន ឆ័យ** និងសហសេរីក មិនមានកង្វល់នឹងរបងផ្ទះរបស់កម្ពុជា ដែលត្រូវប្រឈមនឹងការលំបាកនៅកន្លែងផ្សេងទៀតប៉ុន្មាននោះទេ ។ ហេតុនេះហើយ ទើបពេលនេះ ខ្ញុំត្រូវផ្ដល់ការបំភ្លឺជូនដល់អង្គរដ្ឋសភា និង ប្រជាពលរដ្ឋកម្ពុជាទាំងមូលជ្រាបដើម្បីជម្រះនូវមន្ទិលទាំងឡាយពាក់ព័ន្ធនឹងការងារដោះស្រាយបញ្ហាព្រំដែន តែជាមួយនឹងប្រទេសវៀតណាមមួយប៉ុណ្ណោះ ។

មួយវិញទៀត ដូចបានលើកឡើងពីខាងដើម ខ្ញុំចង់ធ្វើការបញ្ជាក់បន្ថែមខ្លះទៀតអំពីផ្ទៃក្រឡាដីរបស់កម្ពុជា ដែលគេគ្រប់គ្នាចាំរត់មាត់ថាមានទំហំ ១៨១ ០៣៥ គីឡូ-ម៉ែត្រក្រឡានោះ ។ តាមពិត អំពីទំហំផ្ទៃក្រឡានេះ គឺមានតួលេខច្រើនខុសគ្នា និង ចេញពីប្រភពដើមដោយឡែកពីគ្នាគឺ ÷

ទី១- តួលេខ ១៨១ ០៣៥ គីឡូម៉ែត្រក្រឡា ដែលមានប្រើជាផ្លូវការនៅក្នុងសៀវ-ភៅសិក្សាអប់រំជាយូរមកហើយ ។ ពីខាងដើម ខ្ញុំក៏បានសាកល្បងពន្យល់ហើយដែរ អំពីប្រភពនៃការគណនារកតួលេខនេះ ។

ទី២- តួលេខ ១៧៥ ៤៥០ គីឡូម៉ែក្រឡា ដែលតំណាងជាន់ខ្ពស់បារាំងនៅកម្ពុជាបានរាយការណ៍ឱ្យទៅអគ្គទេសាភិបាលឥណ្ឌូចិន បន្ទាប់ពីបានខេត្តបាត់ដំបង សៀមរាប ស៊ីសុផុន ពីសៀមមកវិញ ។

ទី៣- តួលេខ ១៧៩ ០០០ គីឡូម៉ែត្រក្រឡា ដែលខុទ្ទកាល័យអគ្គទេសាភិបាលបារាំង បានកំណត់ឱ្យ ។

ទី៤- តួលេខ ១៨១ ៦០៦ គីឡូម៉ែត្រក្រឡា ដែលអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន បានបង្ហាញឱ្យឃើញ បន្ទាប់ពីធ្វើការគណនាតាមបណ្ដាញកុំព្យូទ័រលើខ្សែព្រំដែនដែលមាននៅលើផែនទីខ្នាត ១/៥០ ០០០ របស់សហរដ្ឋអាមេរិក ។ តែតួលេខនេះត្រូវ

បានកែសម្រួលតាមប្រព័ន្ធព័ត៌មានភូមិសាស្ត្រវិទ្យា Arc-GIS ថ្មី ដែលផ្តល់ឱ្យនូវតួលេខ ២ គឺ : ១៨១ ៤៣៦ គីឡូម៉ែត្រក្រឡា តាមផែនទីខ្នាត ១/២០០ ០០០ (ខ្សែព្រំដែនកម្ពុជា- ថៃ) និង ១៨១ ៣១២ គីឡូម៉ែត្រក្រឡា តាមផែនទីខ្នាត ១/៥០ ០០០ DMA (ខ្សែព្រំដែនកម្ពុជា- ថៃ)។ គួរបញ្ជាក់បន្ថែមថា តួលេខផ្ទៃក្រឡាដីដែលបានគណនានេះ គឺមិនបានបូកបញ្ចូលផ្ទៃដីកោះ ដែលស្ថិតនៅក្នុងដែនសមុទ្រនៃព្រះរាជាណាចក្រកម្ពុជានោះទេ (សូមមើលផែនទី ក្នុងឧបសម្ព័ន្ធទី ៨) ។

ដោយមានតួលេខច្រើនដូច្នេះហើយ ទើបរាជរដ្ឋាភិបាលបានសម្រេចចិត្តប្រើតួលេខ ១៨១ ០៣៥ គីឡូម៉ែត្រក្រឡា បន្តទៀតជាបណ្តោះអាសន្នសិន រហូតដល់ការងារកំណត់ព្រំដែនខណ្ឌសីមាជាមួយប្រទេសទាំងបីគឺ ឡាវ ថៃ និងវៀតណាម បានដំណើរការទៅចប់សព្វគ្រប់ ពីព្រោះ នេះ គឺជាតួលេខដែលយើងបានប្រើប្រាស់ពីដើមរៀងមកដល់បច្ចុប្បន្ន ហើយប្រជាពលរដ្ឋកម្ពុជាក៏បានរៀនសូត្រចេះចាំស្ទាត់មាត់ហើយដែរ ។

ម្យ៉ាងទៀត ខ្ញុំក៏សូមបញ្ជាក់បន្ថែមផងដែរអំពីការផលិតផែនទីខ្នាត ១/២៥ ០០០ ។ ដូចបានជម្រាបពីខាងលើ បន្ទាប់ពីការងារកំណត់ខណ្ឌសីមា និង ការបោះបង្គោលព្រំដែនបានដំណើរការចប់ កម្ពុជា និងវៀតណាម នឹងរួមគ្នាផលិតផែនទីឋានលេខាព្រំដែនមួយដែលមានខ្នាត ១/២៥ ០០០ ដែលមានបង្ហាញទីតាំងបង្គោលព្រំដែន និងខ្សែខណ្ឌសីមាព្រំដែនរវាងប្រទេសទាំងពីរ ។ ក្រុមហ៊ុន BlomInfo A/S នៃប្រទេសដាណឺម៉ាក គឺជាអ្នកដេញថ្លៃបានការងារនេះ ហើយត្រូវទទួលរ៉ាប់រងធ្វើផែនទីនេះ ក្រោមការត្រួតពិនិត្យរបស់អ្នកបច្ចេកទេសចម្រុះនៃប្រទេសទាំងពីរ ។

បន្ថែមលើនេះ ខ្ញុំសូមគូសរំលេចចំណុចមួយទៀត ដែលពាក់ព័ន្ធនឹងអនុស្សារណៈនៃការយោគយល់គ្នា ឆ្នាំ ២០១១ ។ អនុស្សារណៈនៃការយោគយល់គ្នាស្តីពីការកែសម្រួលខ្សែព្រំដែនគោកនៅតំបន់ ដែលនៅសេសសល់មួយចំនួននេះ ត្រូវបានចុះហត្ថលេខានៅថ្ងៃទី ២៣ ខែមេសា ឆ្នាំ ២០១១ ក្នុងគោលដៅដោះស្រាយបញ្ហាគាំងស្ទះមួយចំនួន ដើម្បីរក្សាការគ្រប់គ្រងបច្ចុប្បន្នរបស់ប្រជាពលរដ្ឋនៅតាមព្រំដែន សំដៅជំរុញការអភិវឌ្ឍ កាត់បន្ថយភាពក្រីក្រ និង សម្រួលដល់ការរស់នៅប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋ ។ នេះ គឺជាការចាំបាច់ណាស់ ពីព្រោះ កិច្ចការមានការគាំងស្ទះជា

ច្រើនឆ្នាំមកហើយ ។ មុនដំបូងភាគីទាំងពីរគ្រោងបញ្ចប់ការងារនេះ នៅឆ្នាំ ២០០៨ ។ ក្រោយមក ក៏មានការពន្យារពេលដល់ឆ្នាំ ២០១២ ។ ឥឡូវនៅសល់ ៥ ខែទៀតប៉ុណ្ណោះ ត្រូវដាច់ឆ្នាំ ២០១២ ហើយ ក៏ប៉ុន្តែ ការគាំងស្ទះនៅតែមិនទាន់ត្រូវបានដោះស្រាយនៅឡើយ មានដូចជា ÷

ទីមួយ- ការធ្វើសវនកម្មខ្សែព្រំដែនលើផែនទីនៅសល់ ៥ ផ្ទាំង ។ កិច្ចការនេះ បានដំណើរការជាង ២ ឆ្នាំមកហើយ ក៏ប៉ុន្តែ សូម្បីផែនទីមួយផ្ទាំងក៏មិនទាន់ចេញដែរ ដោយភាគីទាំងពីរពុំឯកភាពគ្នាលើការគូសចម្លងខ្សែព្រំដែន ។

ទីពីរ- ពុំទាន់មានការឯកភាពគ្នា ក្នុងការកំណត់ទីតាំងបង្គោលព្រំដែនមួយចំនួននៅលើដីជាក់ស្តែង និង មិនមានការឯកភាពគ្នា លើខ្សែខណ្ឌសីមាព្រំដែនជាច្រើនកំណាត់ ។

ប្រការទាំងនេះ សរបញ្ជាក់ឱ្យឃើញថា អ្នកបច្ចេកទេសរបស់កម្ពុជាទាំង ៧ ក្រុម ពុំបានធ្វើអ្វីតាមតែអ្នកផ្សេងបង្គាប់ ដូចការចោទប្រកាន់របស់មជ្ឈដ្ឋានមួយចំនួននោះទេ ។ បើពុំដូច្នោះ កិច្ចការដែលនៅសេសសល់ទាំងអស់នេះ ប្រហែលជាត្រូវបានបញ្ចប់តាំងពីយូរណាស់មកហើយ ។ បើជាអាយ៉ង ម៉េចចាំបាច់ទៅចរចា ទាំងព្រំដែនគោក ទាំងព្រំដែនសមុទ្រ ធ្វើអ្វី ?

**សំណួរទី២- ការងារបច្ចេកទេសវាស់វែងរកចំណុចបង្គោលព្រំដែន :**

នេះគឺជាលើកទី ៣ ហើយ ដែលឯកឧត្តម **សុន ឆ័យ** លើកសំណួរដដែលនេះមករាជរដ្ឋាភិបាល ។ ឯកឧត្តមនៅតែពុំយល់ ឬធ្វើជាពុំយល់ អំពីអ្វីដែលរាជរដ្ឋាភិបាលបាន និង កំពុងធ្វើនោះទេ ។ ប្រហែលជាឯកឧត្តមគិតដូចប្រធានរបស់ឯកឧត្តមដែរថា សម្ភារៈវាស់វែងរបស់ក្រុមបច្ចេកទេសព្រំដែន គឺជាល្បែងក្មេងលេងដែលលក់នៅតាមដងវិថី ។

ខ្ញុំសូមធ្វើការបញ្ជាក់ជាថ្មីម្តងទៀតថា ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ក្រុមការងារនៃភាគីទាំងសងខាង ប្រើប្រាស់ឧបករណ៍ និង បច្ចេកវិទ្យាទំនើបៗ ដូចមានបង្ហាញជូនក្នុងរូបភាពនេះ (សូមពិនិត្យបញ្ជីឈ្មោះឧបករណ៍ និងរូបភាពនៃឧបករណ៍ ក្នុងឧបសម្ព័ន្ធទី ៩) ដើម្បីរកវត្ថុធាតុគោលនៅលើដីជាក់ស្តែង ។ គួបផ្សំជាមួយនឹង ឧបករណ៍ទាំងនេះ

យើងនៅបានប្រើប្រាស់ផែនទីបោន (Bonne) ខ្នាត ១/១០០ ០០០ បោះពុម្ពដោយក្រុមភូមិសាស្ត្រឥណ្ឌូចិន សម្រាប់ជាមូលដ្ឋាននៃការវាស់វែង ស្របតាមមាត្រា ២ នៃរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ គួបផ្សំនិងផែនទី UTM ខ្នាត ១/៥០ ០០០ ជាឧបករណ៍ជំនួយក្នុងការចុះវាស់វែងកំណត់ទីតាំងបង្គោលព្រំដែននៅលើដីជាក់ស្តែង ដូចដែលមានចែងក្នុងសន្ធិសញ្ញាបំពេញបន្ថែម ឆ្នាំ ២០០៥ ដែលត្រូវបានរដ្ឋសភា និងព្រឹទ្ធសភាអនុម័ត ហើយព្រះករុណាព្រះមហាក្សត្រ ក៏ទ្រង់បានឡាយព្រះហត្ថលេខាលើព្រះរាជក្រមដាក់ឱ្យប្រើច្បាប់នេះ នាខែវិច្ឆិកា ឆ្នាំ ២០០៥ កន្លងទៅ ។ បន្ថែមលើនេះទៀត យើងក៏ប្រើប្រាស់ផងដែរ នូវផែនទីបោន (Bonne) ដែលបានមកពីការធ្វើសវនកម្មខ្សែព្រំដែនឆ្នាំ ១៩៨៥ ដោយគូសចម្លងពីផែនទីបោន (Bonne) ខ្នាត ១/១០០ ០០០ មកលើផែនទី UTM ខ្នាត ១/៥០ ០០០ ដែលសន្ធិសញ្ញាបំពេញបន្ថែម ឆ្នាំ ២០០៥ អនុញ្ញាតឱ្យប្រើ ។

សរុបសេចក្តីមក ការលើកឡើងថា កម្ពុជាខ្វះខាតបច្ចេកទេស និង ឧបករណ៍វាស់វែង និង ខ្វះខាតធនធានមនុស្សសម្រាប់បំពេញការងារនោះ គឺមិនត្រឹមត្រូវទេ ។ ដូចបានបញ្ជាក់ខាងលើ យើងមានធនធានមនុស្ស និង ឧបករណ៍ទំនើប រួមទាំងមធ្យោបាយដឹកជញ្ជូនគ្រប់គ្រាន់ សម្រាប់ប្រើប្រាស់ក្នុងការបំពេញបេសកកម្មព្រំដែននេះ ឱ្យបានប្រកបដោយប្រសិទ្ធភាពជាមួយនឹងប្រទេសជិតខាងទាំងបី ។

ជាការពិត មន្ត្រីដឹកនាំ និង អ្នកបច្ចេកទេសរបស់យើងឆ្លងកាត់នូវការលំបាករាប់មិនអស់ទេ នៅក្នុងការខិតខំបំពេញភារកិច្ចជាប្រវត្តិសាស្ត្រជូនជាតិមាតុភូមិនៃយើង ។ យើងបានបាត់បង់វីរៈជននៃការងារព្រំដែនរបស់យើង ២ នាក់ដែលបានបូជាជីវិត និងមួយចំនួនទៀត ត្រូវរងរបួសពិការមួយជីវិតដើម្បីបុព្វហេតុជាតិដ៏មានសារសំខាន់នេះ ។ ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ក្រុមបច្ចេកទេសរបស់យើងត្រូវចូលលុកក្នុងព្រៃដែលសម្បូរទៅដោយគ្រាប់មីនបង្កប់តាំងពីសម័យសង្គ្រាមស៊ីវិលមក ជាកន្លែងដែលប្រឈមនឹងជំងឺគ្រុនចាញ់ សត្វសាហាវ គ្មានផ្លូវគមនាគមន៍ទៅដល់ ហើយត្រូវសម្រាកនៅតំបន់ដាច់ស្រយាល ខ្វះកន្លែងបោះជំរុំ គ្មានទឹកស្អាតប្រើប្រាស់ប្រចាំថ្ងៃ ខ្វះអនាម័យ ។ល។ (សូមមើលរូបភាព ក្នុងឧបសម្ព័ន្ធទី ១០) ។

វិវភាពទាំងអស់នេះ គួរតែត្រូវបានមើលឃើញ និង ផ្តល់តម្លៃគោរពកោតសរសើ ។ ក៏ប៉ុន្តែ ផ្ទុយទៅវិញ កិច្ចការមួយចំនួនដែលសម្រេចបានមកដោយលំបាកលំបិននេះ បែរជាត្រូវប្រឈមនឹងការបាត់បង់ ដោយសារមហិច្ឆិតានយោបាយរបស់ក្រុមជនមួយចំនួនតូចទៅវិញ ។ អាស្រ័យហេតុនេះ ខ្ញុំសូមឆ្លៀតយកឱកាសនេះ តាងនាមឱ្យរាជរដ្ឋាភិបាលកម្ពុជាសំដែងនូវការដឹងគុណ និង ការកោតសរសើរដោយស្មោះ ជូនចំពោះក្រុមការងារបច្ចេកទេស និង មន្ត្រីគ្រប់ជាន់ថ្នាក់នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន នៅក្រោមការដឹកនាំរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ អាន** និង ឯកឧត្តមទេសរដ្ឋមន្ត្រី **វ៉ា គឹមហុង** ដែលបានបូជានូវកម្លាំងកាយ ប្រាជ្ញា និង ស្មារតីរបស់ខ្លួនដើម្បីបុព្វហេតុនៃកិច្ចការព្រំដែនដ៏មានសារៈសំខាន់សម្រាប់ប្រទេសជាតិនេះ ។

**សំណួរទី ៣- ការបាត់បង់ភូមិខ្មែរ តាមបណ្តោយព្រំដែន ជាពិសេសភូមិថ្លុកត្រាច និង ភូមិអន្លង់ជ្រៃ :**

យោងតាមផែនទីតម្កល់នៅអង្គការសហប្រជាជាតិ ខ្នាត ១/១០០ ០០០ របស់ក្រុមភូមិសាស្ត្រឥណ្ឌូចិន មួយផ្នែកធំនៃភូមិនេះ ស្ថិតនៅក្នុងទឹកដីខ្មែរ ក្រោមឈ្មោះថា ភូមិអន្លង់ក្រេះ និង មួយផ្នែកតូចនៃភូមិនេះ ស្ថិតនៅក្នុងទឹកដីវៀតណាម (សូមមើលផែនទីក្នុងឧបសម្ព័ន្ធទី ១១) ។

នៅក្នុងស្ថានភាពជាក់ស្តែងរបស់កម្ពុជា នេះគឺជាមរតកដែលបន្សល់ទុកតាំងពីសម័យកាលនៃការត្រួតត្រារបស់បារាំងលើកម្ពុជាមកម្ល៉ះ ។ ដូចបានបញ្ជាក់ពីខាងដើម ការគូសផែនទីបែងចែកទឹកដីនាពេលនោះ ត្រូវបានធ្វើឡើងក្រោមការសម្រេចរបស់រដ្ឋបាលបារាំង ដោយមិនបានសាកសួរ ឬ ពិគ្រោះយោបល់ជាមួយម្ចាស់ប្រទេសនោះឡើយ ។ អ្នកគូសផែនទី ក៏មិនដែលបានដឹង និង ស្គាល់អំពីស្ថានភាពនៃការកាន់កាប់ដីធ្លីរបស់ប្រជាជននៅលើដែនដីជាក់ស្តែងនោះដែរ ។ បន្ថែមលើនេះទៀត ខ្សែបន្ទាត់ព្រំដែន ក៏ត្រូវបានសម្រេចផ្លាស់ប្តូរជាច្រើនសា ដោយរដ្ឋអំណាចមូលដ្ឋាន និង ប្រជាជននៅតាមទីតាំងដែលមានការពាក់ព័ន្ធជាក់ស្តែងមិនបានដឹងឮ ។ល។

ដូច្នេះ នៅក្នុងសភាពការណ៍ជាក់ស្តែង ដែលបន្ទាត់ព្រំដែនភាគច្រើនមានតែនៅលើផែនទី ដោយគ្មានបង្គោលពិតប្រាកដ ហើយផែនទី និង ការកាន់កាប់ជាក់ស្តែង

របស់ប្រជាជន ក៏មិនស្របគ្នា ដែលក្នុងនេះ មានភូមិវៀតណាមចូលខាងដីខ្មែរ ឯភូមិខ្មែរក៏ចូលទៅក្នុងដីវៀតណាមវិញដែរ តើគេត្រូវដោះស្រាយតាមវិធីណា? ជារួម ជម្រើសនៃការដោះស្រាយអាចមានបីយ៉ាង គឺ ÷

ទីមួយ- កាត់ភូមិខ្មែរដែលនៅក្នុងដីវៀតណាម រួមទាំងប្រជាជនខ្មែរនៅក្នុងនោះផង បញ្ចូលទៅឱ្យវៀតណាម ដើម្បីឱ្យស្របតាមផែនទី ហើយវៀតណាម ក៏ត្រូវធ្វើដូចគ្នាដែរ ចំពោះភូមិ និង ប្រជាជនរបស់ខ្លួន ដែលស្ថិតនៅលើទឹកដីកម្ពុជា ។

ទីពីរ- រើភូមិ និងប្រជាជនរៀងៗខ្លួន ចេញពីទីតាំងដែលឆ្លងចូលគ្នាទៅវិញទៅមកនោះ ហើយកាត់ទឹកដីដែលឆ្លងចូលគ្នានេះ ឱ្យគ្នាទៅវិញទៅមក ដើម្បីសម្របតាមផែនទីដោយមិនចាំបាច់គិតអំពីកត្តាសេដ្ឋកិច្ច សង្គម និង ប្រវត្តិសាស្ត្រនៃការកាន់កាប់ដីធ្លី និងការរស់នៅរបស់ប្រជាជន ក្នុងរយៈពេលដ៏យូរលង់កន្លងមកនោះឡើយ ។

ទីបី- រក្សាការកាន់កាប់របស់ប្រជាជនទាំងសងខាង នៅតាមទីតាំងដដែលរៀងៗខ្លួន ដោយធ្វើការសម្របសម្រួលដោះដូរជាមួយគ្នា ស្របតាមស្មារតីអនុស្សារណៈនៃការយោគយល់គ្នា ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១១ ។

វិធីសាស្ត្រទីបីចុងក្រោយនេះ គឺជាជម្រើសដ៏ល្អប្រសើរជាងគេសម្រាប់ប្រជាពលរដ្ឋនៃភាគីទាំងសងខាងនៅតាមទីតាំងដែលមានការប៉ះពាល់ ។ ដូចបានបញ្ជាក់ពីខាងលើ អនុស្សារណៈនៃការយោគយល់នេះ ត្រូវបានធ្វើឡើងដើម្បីគោលដៅបន្តរក្សាការគ្រប់គ្រងកាន់កាប់ភូមិករ និងដីធ្លីស្រែចំការរបស់ប្រជាពលរដ្ឋ ដែលបានតាំងទីលំនៅ និងធ្វើការបង្កបង្កើនផលជាយូរឆ្នាំមកហើយ ឱ្យបានបន្តរស់នៅ និង កាន់កាប់ដីធ្លីទាំងនោះដដែល ។ នៅក្នុងក្របខ័ណ្ឌនៃការងារនេះ ក្រុមជំនាញចម្រុះនឹងត្រូវចុះសិក្សាលម្អិតមុននឹងធ្វើការដោះដូរគ្នា **«ស្មើទៅ- ស្មើមក»** ទៅតាមលក្ខណៈភូមិសាស្ត្រ និងស្ថានភាពដី ដោយយកខ្សែគូសចម្លងពីផែនទីបោន (Bonne) ខ្នាត ១/១០០ ០០០ របស់ក្រុមភូមិសាស្ត្រឥណ្ឌូចិន មកលើផែនទី UTM ធ្វើជាមូលដ្ឋាន ស្របតាមការអនុញ្ញាតនៃសន្និសីទបំពេញបន្ថែម ។ គោលការណ៍សំខាន់នៅទីនេះ គឺធានាឱ្យបានដាច់ខាតថាកម្ពុជានឹងមិនខាត ឬ បាត់បង់ដីឡើយ សូម្បីតែ ១ ម៉ែត្រក្រឡាក៏ដោយ។

ទោះជាមានគម្រោងធ្វើការដោះដូរដូច្នេះមែនក្តី តែយើងនៅរក្សាផ្ទៃដីសរុបឱ្យនៅដដែល ព្រោះវាជាការដោះដូរ **«ស្មើទៅ- ស្មើមក»** ពោលគឺ បើ ១ ហិកតាទៅ គឺត្រូវបាន ១ ហិកតាមកវិញ នៅក្នុងខេត្តជាមួយគ្នា លើកលែងតែករណីក្នុងខេត្តនោះពុំមានដីដោះដូរ ទើបអនុញ្ញាតឱ្យឆ្លងទៅដូរជាមួយនឹងខេត្តមួយផ្សេងទៀតបាន ដើម្បីធ្វើការទូទាត់សងគ្នាឱ្យបានស្មើ និង គ្រប់ចំនួន ។ ការធ្វើដូច្នេះ គ្មានអ្វីផ្ទុយនឹងច្បាប់ជាតិ ក៏ដូចជាច្បាប់អន្តរជាតិ ដូចមតិមួយចំនួនធ្វើការចោទប្រកាន់នោះទេ ព្រោះថា នេះ គឺជាមរតកប្រវត្តិសាស្ត្រដែលអាណានិគមបន្សល់ទុកឱ្យ ហើយវាក៏មិនមែនជាករណីរំលោភឈ្លានពានចូលយកទឹកដីពីសំណាក់ភាគីណាមួយនោះដែរ ។ លើសពីនេះទៀត ការអនុវត្តបែបនេះ ក៏សមស្របផងដែរ ទៅនឹងគោលការណ៍នៃការសម្រុះសម្រួលគ្នា ដែលត្រូវបានអនុវត្តជាអន្តរជាតិ និង ត្រូវបានលើកទឹកចិត្តឱ្យអនុវត្តដោយអង្គការសហប្រជាជាតិ និង តុលាការយុត្តិធម៌អន្តរជាតិក្រុងឡាអេ ។

រហូតមកដល់ពេលនេះ ខ្ញុំសូមបញ្ជាក់ថា ពុំមានភូមិខ្មែរណាមួយ ត្រូវបានបាត់បង់នោះទេ ។ ម៉្យាងវិញទៀត ដូចបានបញ្ជាក់អម្បាញមិញ ករណីដោះដូរនេះ ពុំមែនមានតែនៅកម្ពុជា និង វៀតណាមនោះទេ ។ វៀតណាម និង ឡាវ, វៀតណាម និង ចិន ក៏បានអនុវត្តតាមវិធីសាស្ត្រនេះដែរ ។ ឧទាហរណ៍បែបនេះមានច្រើនណាស់នៅតាមតំបន់ និង ទ្វីបផ្សេងទៀត រួមមានដូចជា បារាំង និង បែលហ្ស៊ិក ដែលបានបន្តដោះដូរដីជាមួយគ្នា ខណៈដែលប្រទេសទាំងពីរបានទទួលស្គាល់ព្រំដែនគ្នាតាំងពីឆ្នាំ ១៨៣០ ។ បែលហ្ស៊ិក និង ហូឡង់ ក៏បានធ្វើការដោះដូរដីដូចគ្នាដែរ ។ គេធ្វើនេះ គឺដើម្បីសម្របសម្រួលទៅនឹងការកាន់កាប់ជាក់ស្តែងនៅលើដែនដី និង ដើម្បីងាយស្រួលធ្វើការគ្រប់គ្រងលើទ្រព្យសម្បត្តិផង ព្រមទាំងសម្រួលជីវភាពរស់នៅរបស់ប្រជាពលរដ្ឋគេផង ។ ប្រទេសឆេក និង ស្លូវ៉ាក ក៏បានដោះដូរភូមិ និង ដីជាមួយគ្នាដែរ ក្រោយពីប្រទេសទាំងពីរនេះ បានបែកគ្នាចេញពីប្រទេសឆេកូស្លូវ៉ាគី ។

រីឯនៅកម្ពុជាយើង បញ្ហាដោះដូរដីនេះ ក៏មិនមែនជារឿងថ្មីថ្មោងនោះដែរ ។ ការដោះដូរនេះ កើតមានឡើងតាំងពីឆ្នាំ ១៩៤២ មកម្ល៉េះ ។ យោងតាមអនុក្រឹត្យ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៤២ អគ្គទេសាភិបាលឥណ្ឌូចិនបានសម្រេចធ្វើការដោះដូរកោះ

គគី ស្ថិតនៅឃុំព្រែកជ្រៃ ស្រុកកោះធំ ខេត្តកណ្ដាល (កម្ពុជា) ជាមួយនឹងដីមួយដុំ ដែលមានទទឹង ២០០ ម៉ែត្រ និងបណ្ដោយប្រមាណ ២ ៥០០ ម៉ែត្រ តាមព្រែកប៊ីញយី ខេត្តចូវដុក(កូសាំងស៊ីន) ។ ការដោះដូរនេះ ត្រូវបានព្រះមហាក្សត្រ **នរោត្តម សីហនុ** ទទួលយក តាមរយៈព្រះរាជក្រម ចុះថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ១៩៤២ ដោយបានបញ្ចូលដី នៅព្រែកប៊ីញយីនេះ ទៅក្នុងឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្ដាលរបស់កម្ពុជា តាំងពី ពេលនោះមក ។

ឥឡូវនេះ យើងវិលមកនិយាយអំពីភូមិថ្លុកត្រាច និង ភូមិអន្លុងជ្រៃវិញ ។ បច្ចុប្បន្ន ភូមិទាំងពីរនេះ ត្រូវបានភាគីទាំងពីរឯកភាពឱ្យក្រុមបច្ចេកទេសចម្រុះ ចុះទៅធ្វើការវាស់ វែង ដើម្បីគណនារកផ្ទៃក្រឡាដីចេញ- ចូលពិតប្រាកដ រួចហើយទុកធ្វើការទូទាត់ឱ្យគ្នា ទៅវិញទៅមកនៅពេលក្រោយ តាមគោលការណ៍ដូចបានបញ្ជាក់ខាងលើ ។ បន្ថែមលើ នេះ ខ្ញុំសូមបញ្ជាក់ថា ភូមិអន្លង់ជ្រៃនេះ ពុំមាននៅក្នុងផែនទីមណ្ឌលរដ្ឋបាលកូសាំង- ស៊ីន ឆ្នាំ ១៨៧៣ ដូចការអះអាងពីអ្នកជំនាញឯនាយសមុទ្រនោះទេ (សូមមើលផែនទី មណ្ឌលរដ្ឋបាលកូសាំងស៊ីន ឆ្នាំ ១៨៧៣ ក្នុងឧបសម្ព័ន្ធទី ១២) ។

ដោយឡែក ពាក់ព័ន្ធនឹងវឌ្ឍនភាពនៃការងារវាស់វែងផ្ទៃដីចេញ- ចូលសម្រាប់ ការដោះដូរគ្នានេះ ខ្ញុំសូមជម្រាបជូនថា ជារួម ក្រុមការងារបច្ចេកទេសបានធ្វើការវាស់ វែងផ្ទៃដីចេញ- ចូលគ្នា ទៅវិញទៅមកនេះ នៅគ្រប់ខេត្តទាំង ១០ រួចហើយ ដែលក្នុង នោះ នៅខេត្តភាគច្រើន ខាងកម្ពុជាបានធ្វើការវាស់វែងជាឯកតោភាគី ដោយមិនទាន់ មានការទទួលស្គាល់ជាទ្វេភាគីនៅឡើយ លើកលែងតែខេត្ត កំពង់ចាម កំពត និងតាកែវ ដែលក្រុមបច្ចេកទេសចម្រុះបានចុះហត្ថលេខាទទួលយកជាទ្វេភាគីហើយ ប៉ុន្តែ ប្រធាន គណកម្មាការចម្រុះព្រំដែននៃប្រទេសទាំងពីរ មិនទាន់បានអនុម័តទទួលយកកំណត់- ហេតុនេះនៅឡើយ ។ សរុប ការវាស់វែងផ្ទៃដីចេញ- ចូលគ្នាទូទាំងខ្សែព្រំដែនរវាង កម្ពុជា- វៀតណាម ទាំងតួលេខដែលបានឯកភាពគ្នា ទាំងតួលេខដែលមិនទាន់បាន ឯកភាពគ្នា ឃើញថា កម្ពុជាគ្រប់គ្រងចូលដីវៀតណាម មានចំនួនប្រមាណជា ៩១៦,៧ ហិកតា ។ រីឯវៀតណាមវិញ គ្រប់គ្រងចូលដីកម្ពុជា មានចំនួនប្រមាណជា ២ ១៦០,៦ ហិកតា ។ ទៅថ្ងៃអនាគត បើតួលេខនេះត្រូវបានទទួលស្គាល់ដោយភាគីទាំងសងខាង

ជាតួលេខផ្លូវការ នោះវៀតណាមត្រូវរកដីសងឱ្យកម្ពុជាប្រមាណជា ១ ២៤៣,៩ ហិកតា ដែលនេះ គឺជាដំណោះស្រាយតាម MOU ឆ្នាំ ២០១១ (សូមមើលផែនទីខេត្តទាំង ៤ ក្នុងឧបសម្ព័ន្ធទី ១៣) ។ គួរបញ្ជាក់បន្ថែមថា ផ្ទៃដីចេញ- ចូលនេះ មិនមែនកើតមកពីប្រជាជនកម្ពុជាបំពានលើដីវៀតណាម ឬប្រជាជនវៀតណាមបំពានលើដីកម្ពុជានោះទេ ។ ក៏ប៉ុន្តែ បញ្ហានេះ បណ្តាលមកពីខ្សែព្រំដែនដែលបារាំងបានគូសលើផែនទីបន្សល់ទុកឱ្យ ដែលភាគីទាំងពីរ កម្ពុជា- វៀតណាម ត្រូវរកដំណោះស្រាយសំដៅរក្សាទុកស្ថានភាពនៃការកាន់កាប់ភូមិករ ដីធ្លី និង ទ្រព្យសម្បត្តិរបស់ប្រជាជនទាំងសងខាង ។

**សំណួរទី៤- បង្គោលព្រំដែនលេខ ៣១៤ និង ការធានា បូរណភាពទឹកដីកម្ពុជា :**

រហូតមកដល់ពេលនេះ យើងបានបោះបង្គោលព្រំដែន សម្រេចបានចំនួន ២៣៦ ទីតាំង លើចំនួនទីតាំងសរុប ៣១៤ ។ គិតជាចំនួនបង្គោល គឺសម្រេចបានចំនួន ២៨៥ លើ ៣៧៥ បង្គោល (ទោល ភ្លោះ ត្រី) ដែលត្រូវជា ៧៦% នៃចំនួនបង្គោលសរុប ។ ក្នុងនេះ ទីតាំងដែលបានសាងសង់រួច មានចំនួន ២០៨ លើ ៣១៤ ។ គិតជាបង្គោល គឺស្មើនឹង ២៥២ លើ ៣៧៥ បង្គោល ។ ការងារខណ្ឌសីមាព្រំដែន សម្រេចបានប្រវែង ៧០០ គីឡូម៉ែត្រ នៃខ្សែព្រំដែនសរុបដែលមានប្រវែងប្រមាណជា ១ ២៧០ គីឡូម៉ែត្រ ពោលគឺ ស្មើនឹង ៥៨% នៃខ្សែព្រំដែនទាំងមូល ។

ខ្ញុំសូមបញ្ជាក់ជូនថា បង្គោលព្រំដែនលេខ ៣១៤ គឺជាបង្គោល ចុងក្រោយបំផុតនៃខ្សែព្រំដែនគោករវាងប្រទេសទាំងពីរកម្ពុជា- វៀតណាម ។ ចំពោះមុខ កម្ពុជាមានគោលដៅបន្តឆ្ពោះទៅកំណត់ព្រំដែនសមុទ្រ នៅក្នុងឈូងសមុទ្រសៀមបន្ថែមទៀត ដោយចាប់ផ្តើមចេញពីបង្គោលព្រំដែនលេខ ៣១៤ នេះទៅ ។ បង្គោលនេះមានសារ-សំខាន់ណាស់ ទោះជាក្នុងរូបភាពនៃជម្រើសខ្សែព្រំដែនណាមួយក៏ដោយ ពោលគឺ ទាំងជម្រើសប្រើខ្សែប្រេវីយ៉េឆ្នាំ ១៩៣៩ ទាំងជម្រើសប្រើខ្សែសមចម្ងាយ ពីព្រោះថា ភាគីទាំងពីរចាំបាច់ត្រូវធ្វើការចរចាគ្នា ដោយផ្តើមចេញពីចំណុចដីគោកនេះ ដើម្បីកំណត់ខ្សែព្រំដែនសមុទ្ររវាងប្រទេសទាំងពីរ ។

ឆ្លៀតក្នុងឱកាសនេះដែរ ខ្ញុំសូមលើកឡើងនូវជំហរដ៏ត្រឹមត្រូវ និង ភ្លឺស្វាងមួយរបស់ព្រះករុណា សម្តេចព្រះ **នរោត្តម សីហនុ** ដែលព្រះអង្គបានបញ្ជាក់នៅក្នុងព្រះ-

រាជសារចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ១៩៩៩ ថា: ***«ក្នុងប្រវត្តិសាស្ត្រកម្ពុជា ទឹកដីកម្ពុជាក្រោមទាំងមូលបានបាត់បង់រួចទៅហើយ ។ បន្ទាប់មក កោះត្រល់ដែលវៀតណាមឱ្យឈ្មោះថា ហ្វូកុកនោះ និង កោះមួយចំនួនដែលស្ថិតនៅខាងត្បូងខ្សែបន្ទាត់ប្រេវីយ៉េ ក៏បន្តបាត់ទៀត ដោយសារសារាចររបស់លោកអគ្គទេសាភិបាលបារាំង ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៣៩ ។ ម្យ៉ាងវិញទៀត កាលពីឆ្នាំ ១៩៦៤ រាជរដ្ឋាភិបាលកម្ពុជាពេលនោះ បានយកផែនទី ១ ដែលបោះពុម្ពដោយក្រុមភូមិសាស្ត្រកម្ពុជាផ្អែកតាមផែនទីបារាំង Service Hydro-graphique ខ្នាត ១/៣០០ ០០០ ភ្ជាប់ជាមួយផែនទីដីគោក ទៅឱ្យអន្តរជាតិទទួលស្គាល់ និង បានតម្កល់ទុកនៅអង្គការសហប្រជាជាតិនោះ គឺយើងបានគូសខ្សែប្រេវីយ៉េជាព្រំដែនសមុទ្រជាមួយវៀតណាមផងដែរ ។ ផែនទី និង ឯកសារទាំងអស់នេះហើយ ដែលអតីតរាជរដ្ឋាភិបាលរបស់ខ្ញុំ អតីតរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា រដ្ឋកម្ពុជា និងរាជរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្ន កំណត់ថាជាព្រំដែនបច្ចុប្បន្នរបស់កម្ពុជា ។ ដូច្នេះហើយ ខ្ញុំយល់ឃើញថាសម័យកាលបច្ចុប្បន្ននេះ ដែលសកលលោកទាំងមូល កំពុងស្វែងរកការសម្របសម្រួលអំពីព្រំដែន យើងគួរយកខ្សែប្រេវីយ៉េនេះ ដើម្បីខណ្ឌព្រំសីមាដែនសមុទ្ររបស់ប្រទេសយើងទាំងពីរ ដើម្បីទុកឱ្យកូនចៅយើងជំនាន់ក្រោយទទួលបាននូវមរតកមួយដ៏ច្បាស់លាស់ សម្រាប់ការគ្រប់គ្រង និង អភិវឌ្ឍន៍ប្រទេសរៀងៗខ្លួន»*** (សូមអានខ្លឹមសារទាំងស្រុងនៃព្រះរាជសារ ក្នុងឧបសម្ព័ន្ធទី ១៤) ។

បង្គោលព្រំដែនដែលភាគីទាំងពីរកម្ពុជា- វៀតណាម បាន និង កំពុងធ្វើនេះ មិនត្រឹមតែជាកិច្ចការរួមគ្នាធ្វើឡើង ដើម្បីសម្គាល់ការខណ្ឌចែកទឹកដីរវាងព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋសង្គមនិយមវៀតណាមប៉ុណ្ណោះទេ ប៉ុន្តែ វាជាចំណែកមួយយ៉ាងសំខាន់ដែលនឹងផ្តល់ជាវិភាគទានមិនអាចកាត់ថ្លៃបានដល់កិច្ចការពារបូរណភាពដែនដីនៃព្រះរាជាណាចក្រកម្ពុជា ឱ្យកាន់តែមានភាពរឹងមាំ និង រួមចំណែកដល់ការធានាសុខសន្តិភាព ការជំរុញលើកស្ទួយកំណើនសេដ្ឋកិច្ច ការអភិវឌ្ឍសង្គម ការលើកកម្ពស់ជីវភាពរស់នៅ និង ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនទៀតផង (សូមមើលរូបភាពបង្គោល ក្នុងឧបសម្ព័ន្ធទី ១៥) ។

- **សម្តេចចក្រី ប្រធានរដ្ឋសភា**
- **ឯកឧត្តម លោកជំទាវ លោក លោកស្រី !**

នៅចុងបញ្ចប់នេះ ខ្ញុំសូមគូសបញ្ជាក់ជាថ្មីម្តងទៀត អំពីការប្តេជ្ញាដ៏មោះមុតឥតងាករេរបស់រាជរដ្ឋាភិបាល ក្នុងការបន្តពុះពារជំនះគ្រប់ឧបសគ្គ ដើម្បីបន្តដំណើរឆ្ពោះទៅសម្រេចឱ្យខាងតែបាននូវគោលដៅជាយុទ្ធសាស្ត្ររបស់ខ្លួន ក្នុងការកសាងខ្សែបន្ទាត់ព្រំដែនកម្ពុជាមួយ ដែលមានភាពច្បាស់លាស់ ត្រឹមត្រូវ ជាព្រំដែនសន្តិភាព មិត្តភាព សហប្រតិបត្តិការ និង ការអភិវឌ្ឍ ដើម្បីឧត្តមប្រយោជន៍របស់ប្រទេសជាតិ និងប្រជា-ជនកម្ពុជាគ្រប់ស្រទាប់ជាន់ថ្នាក់ ។

ជាមួយគ្នានេះ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំក៏សូមសំដែងនូវការដឹងគុណដ៏ជ្រាលជ្រៅផងដែរ ជូនចំពោះអង្គរដ្ឋសភាដ៏ឧត្តុងឧត្តម ដែលជានិច្ចកាល តែងផ្តល់នូវការគាំទ្រដ៏មានតម្លៃចំពោះគោលនយោបាយ និងរាល់សកម្មភាពរបស់រាជរដ្ឋាភិបាល ។ ខ្ញុំសូមសំដែងអំណរគុណជាពិសេស ចំពោះសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និង អង្គរដ្ឋសភាទាំងមូល ដែលបានអនុញ្ញាតឱ្យរូបខ្ញុំដឹកនាំសហការីមកផ្តល់ការបំភ្លឺជូនដល់អង្គរដ្ឋសភា និង តាមរយៈអង្គរដ្ឋសភាដ៏ឧត្តុងឧត្តមនេះ ជូនដល់ប្រជាជនកម្ពុជាទាំងមូល លើប្រធានបទដ៏មានសារសំខាន់ស្តីពីការងារបោះបង្គោលព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋសង្គមនិយមវៀតណាម ។

ខ្ញុំសូមប្រសិទ្ធពរជ័យបវរមហាប្រសើរ ជូនសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និងសមាជិក- សមាជិកាទាំងអស់នៃអង្គរដ្ឋសភា សូមបានប្រកបដោយសុខភាពល្អបរិបូណ៌ និងសម្រេចបានជោគជ័យត្រចះត្រចង់ក្នុងគ្រប់ភារកិច្ច ដើម្បីបុព្វ-ហេតុជាតិ និង ប្រជាជន ។

**សូមអរគុណ !**

ផែនទីមណ្ឌលរដ្ឋបាលតៃនិញ  បង្ហាញទីតាំងបង្គោលព្រំដែនពីលេខ ០១-៣៣

រវាងកម្ពុជា-កូសាំងស៊ីន



ផែនទីមណ្ឌលរដ្ឋបាលតាន់ អាន បង្ហាញទីតាំងបង្គោលព្រំដែនពីលេខ ៣៤-៦០

រវាងកម្ពុជា-កូសាំងស៊ីន



ផែនទីមណ្ឌលរដ្ឋបាលចូវ ដុក បង្ហាញទីតាំងបង្គោលព្រំដែនពីលេខ ៦០-១២៤

រវាងកម្ពុជា-កូសាំងស៊ីន



ផែនទី បង្ហាញពីគ្រឹះបង្គោលសេសសល់ក្នុងមណ្ឌលរដ្ឋបាលចូវដុក



រូបភាពបង្គោលព្រំដែនរវាងកម្ពុជា-កូសាំងស៊ីន បោះនៅទសវត្សរ៍ ឆ្នាំ១៨៦០-១៨៧០





រូបភាពបង្គោលព្រំដែនរវាងកម្ពុជា-កូសាំងស៊ីន
បោះនៅទសវត្សរ៍ ឆ្នាំ១៨៦០-១៨៧០





ផែនទីព្រំដែនគោក តម្កល់ទៅ អ.ស.ប ឆ្នាំ១៩៦៤

ផែនទីព្រំដែនគោក កម្ពុជាឡាវ ភ.ស.ប ឆ្នាំ១៩៦៤



*(បកប្រែក្រៅផ្លូវការ)*

**សេចក្តីប្រកាសព័ត៌មាន**
ចុះថ្ងៃទី ១៧ ខែមករា ឆ្នាំ១៩៩៥
រវាង
នាយករដ្ឋមន្ត្រីវៀតណាម
និង
នាយករដ្ឋមន្ត្រីកម្ពុជា

៨. ភាគីទាំងពីរបញ្ជាក់សារជាថ្មីពីឆន្ទៈរបស់ខ្លួនក្នុងការកសាងព្រំដែនរវាងប្រទេសទាំងពីរឲ្យក្លាយទៅជាព្រំដែនសន្តិភាព មិត្តភាព និងស្ថេរភាព ដើម្បីចូលរួមក្នុងការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការ និងភាពអ្នកជិតខាងល្អ រវាងប្រទេសទាំងពីរ ។ ដោយរង់ចាំដំណោះស្រាយលើបញ្ហាព្រំដែនដ៏សំខាន់នេះ ភាគីទាំងពីរឯកភាពរក្សាស្ថានភាពការគ្រប់គ្រងបច្ចុប្បន្ន ដោយមិនឲ្យមានការផ្លាស់ប្តូរឬរំកិលបង្គោលព្រំដែន និងអប់រំប្រជាជន ដោយហាមប្រាមពួកគាត់មិនឲ្យធ្វើស្រែចំការ ឬតាំងទីលំនៅឆ្លងកាត់ព្រំដែន និងសហការគ្នារក្សាបាននូវព្រំដែនសុវត្ថិភាព និងសណ្តាប់ធ្នាប់ ។

ផែនទី ខ្សែប្រេវីយេ” ឆ្នាំ១៩៣៩ តម្កល់នៅ អ.ស.ប



## ខ្សែវៀតណាមខាងត្បូង ឆ្នាំ១៩៧១



ឧបសម្ព័ន្ធទី ៦/១

## ផែនទី តាមក្រឹត្យសាធារណរដ្ឋខ្មែរ ឆ្នាំ១៩៧២



# ខ្សែសាធារណរដ្ឋខ្មែរ ឆ្នាំ ១៩៧២



# ផែនទី តំបន់ទឹកប្រវត្តិសាស្ត្រ ឆ្នាំ១៩៨២



# គំនូសផែនទីភ្ជាប់ជាមួយក្រឹត្យលេខ ១ក្រ ចុះថ្ងៃទី៣១/៧/១៩៨២



# ខ្សែសមចម្ងាយដែលវៀតណាមទាមទារ




ព្រះរាជាណាចក្រកម្ពុជា
ប្រទេសថៃ
ប្រទេសឡាវ
ប្រទេសវៀតណាម
ឈូងសមុទ្រសៀម
ទំហំផ្ទៃ ១៨១ ៤៣៦ គីឡូម៉ែត្រក្រឡា
កំណត់សំគាល់ :
-ក្រឡាផ្ទៃដោយពុំគិតដីកោះ និងខ្សែព្រំប្រទល់ បានត្រូវគណនាដោយកម្មវិធី GIS-ArcMap
-ខ្សែព្រំប្រទល់អន្តរជាតិជាមួយថៃ គូរតាមផែនទីមាត្រដ្ឋាន១:២០០០០០នៃសន្ធិសញ្ញាបារាំង-សៀមឆ្នាំ១៩០៤-១៩០៧
-ខ្សែព្រំប្រទល់អន្តរជាតិជាមួយឡាវ និងវៀតណាម គូរតាមផែនទីមាត្រដ្ឋាន១:១០០០០០របស់ក្រុមភូមិសាស្ត្រឥណ្ឌូចិន
-ខ្សែឆ្នេរសមុទ្រ គូរតាមអរតូផូតូផលិតឆ្នាំ២០០៥
-ចំណោលផែនទី : Universal Transverse Mercator-UTM, Zone48N, Ellisoid: WGS84
-ប្រព័ន្ធនិយាមកា-ដាតទុម : WGS84
សញ្ញាសំគាល់
ខ្សែព្រំប្រទល់ជាមួយ :
វៀតណាម
ឡាវ
ថៃ
ខ្សែឆ្នេរសមុទ្រ
មាត្រដ្ឋាន ១:២៧00000
103°0'0"E
104°0'0"E
105°0'0"E
106°0'0"E
107°0'0"E
14°0'0"N
13°0'0"N
12°0'0"N
11°0'0"N

**ឧបករណ៍ប្រើប្រាស់ក្នុងការវាស់វែងព្រំដែន :**

- *GPS Garmin 76Csx*
- *Total Station Leica-TPS1200*
- *Total Station Topcon GTS-N100*
- *Total Station Sokia*
- *GPS Dual Frequency Leica-1200*

ឧបករណ៍វាស់វែងពីផ្កាយរណប GPS Dual Frequency Leica-1200





ឧបករណ៍វាស់វែងពីផ្កាយរណប GPS Dual Frequency





ការលើកបង្គោលតម្រង់ទិស ដើម្បីវាស់វែងដោយប្រើឧបករណ៍ Total Station



# បណ្តាញវាស់វែងប្រេចពីវិភាគ ដើម្បីកំណត់និន្នន័យមូលដ្ឋានរូមរវាងកម្ពុជា-វៀតណាម ដោយភ្ជាប់ជាមួយបណ្តាប្រទេសក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិច ឧបករណ៍ GPS Dual Frequency

Plain Observation GPS Network
for Border CAMBODIA-VIET NAM




## Network Adjustment Report

*Project : Cambodia*

| | | | |
|---|---|---|---|
| User name | Mr. SIN SOTHEANY | Date & Time | 10/28/2009 |
| Coordinate System | UTM | Zone | 48 North |
| Project Datum | ITRF2000 | | |
| Vertical Datum | | Geoid Model | EGM96 (Global) |
| Coordinate Units | Meters | | |
| Distance Units | Meters | | |
| Height Units | Meters | | |

Adjustment I

### Adjusted Coordinates

Adjustment performed in ITRF2000

Number of Points : 14
Number of Constrained Points : 3
Horizontal and Height Only : 3

Adjusted Grid Coordinates Errors are reported using 1.96σ.

| Point Name | Northing | N error | Easting | E error | Elevation | e error |
|---|---|---|---|---|---|---|
| N-11 | 1378959.941m | 0.008m | 736839.907m | 0.008m | 700.378 | N/A |
| N16 | 1519708.935m | 0.006m | 714655.888m | 0.007m | 315.060 | N/A |
| N-21 | 1213406.023m | 0.002m | 477047.778m | 0.003m | 6.530 | N/A |
| PENH | 1279428.548m | 0.000m | 491013.771m | 0.000m | N/A | N/A |
| 301 | 1306372.900m | 0.005m | 629903.321m | 0.005m | 87.942 | N/A |
| STUE | 1496014.008m | 0.000m | 605070.839m | 0.000m | N/A | N/A |
| NT04 | 1137764.332m | 0.004m | 449907.651m | 0.004m | N/A | N/A |
| Siha | 1173319.045m | 0.000m | 338477.631m | 0.000m | N/A | N/A |
| KT-A | 1589133.218m | 0.010m | 825575.570m | 0.012m | 542.839 | N/A |
| QT03 | 1779875.374m | 0.013m | 844578.897m | 0.016m | N/A | N/A |
| DL-B | 1403920.291m | 0.012m | 829318.023m | 0.013m | 451.090 | N/A |
| BP-C | 1275911.504m | 0.007m | 705707.318m | 0.007m | 93.453 | N/A |
| QT04 | 1145179.178m | 0.010m | 728490.999m | 0.010m | N/A | N/A |
| LA-D | 1189842.923m | 0.005m | 602242.746m | 0.005m | 3.9380 | N/A |

**ការរុករកវត្ថុធាតុគោល** ៖ វត្ថុសម្គាល់ ឬ វត្ថុយោងនៅលើដីជាក់ស្តែង ដូចជា វត្តអារាម សាលារៀន ស្ទឹង ព្រែក សញ្ញាសំគាល់...





**ការរុករកវត្ថុធាតុគោល** ៖ វត្ថុសម្គាល់ ឬ វត្ថុយោងនៅលើដីជាក់ស្តែង ដូចជា វត្តអារាម សាលារៀន ស្ទឹង ព្រែក សញ្ញាសំគាល់. . .






**ការរុករកវត្ថុធាតុគោល** ៖ វត្ថុសម្គាល់ ឬ វត្ថុយោងនៅលើដីជាក់ស្តែង ដូចជា វត្តអារាម សាលារៀន ស្ទឹង ព្រែក សញ្ញាសំគាល់...






ផែនទី BONNE តំបន់ភូមិអន្លង់ព្រៃ និងភូមិថ្លុកត្រាច ខេត្តកំពង់ចាម
Tânot
Vat
125
126
127
128
129
130
49 hectar
122 hectar
ភូមិអន្លង់ព្រៃ
ភូមិថ្លុកត្រាច
Ph. Ampil
Ph. Aulong Krès
Péam
កម្ពុជា
វៀតណាម
ខ្សែព្រំដែនកម្ពុជា-វៀតណាមថ្មី
តំបន់ដីដោះដូរ (កម្ពុជាកាន់កាប់)
ខ្សែព្រំដែនកម្ពុជា-វៀតណាម
ខ្សែព្រំដែនកម្ពុជា-វៀតណាមថ្មី
តំបន់ដីដោះដូរ (កម្ពុជាកាន់កាប់)
Scale 1:30 000
Map Projection Bonne
209-E and 210-W
អ.ជ.ព.ជ ០៦.៧.២០១២


Scale 1:30 000
Map UTM : Datum Indian1960
Tônlé Méanchey
Stoeng Toch
Ph Anlũng Chrey
Vatt Thkov
Ph Ampil
Ford
Tà Nôt


ផែនទីរូបថតពីលើអាកាស បង្ហាញដីតំបន់ភូមិអន្លង់ជ្រៃ និងថ្លុកត្រាច ខេត្តកំពង់ចាម
125
126
127
128
129
130
49 hectar
122 hectar
ខ្សែព្រំដែនតាមផែនទី បោន
តំបន់ដីដោះដូរ
ខ្សែព្រំដែនតាមការដោះដូរ
ខ្សែព្រំដែនតាមផែនទី បោន
ខ្សែព្រំដែនតាមការដោះដូរ
កម្ពុជា
វៀតណាម
ភូមិអន្លង់ជ្រៃ
ភូមិថ្លុកត្រាច
Map Projection UTM ; Map datum WGS84
map Scale 1:30 000

ផែនទីមណ្ឌលរដ្ឋបាលតៃនិញ បង្ហាញទីតាំងបង្គោលព្រំដែនពីលេខ ០១-៣៣

រវាងកម្ពុជា-កូសាំងស៊ីន




Scale 1:70 000
Map Projection UTM ; Datum Indian 1960


ផែនទីបង្ហាញទីតាំង និងលទ្ធផលបោះបង្គោល ខណ្ឌសីមាព្រំដែន តាមបណ្តោយព្រំដែនខាងខេត្ត ស្វាយរៀង (កម្ពុជា) និងឡុងអាន តៃនិញ (វៀតណាម)
កំណត់សំគាល់
លទ្ធផលការងារក្នុងឆ្នាំ២០១០
លទ្ធផលការងារប្រចាំឆ្នាំ២០១០ របស់ក្រុមបច្ចេកទេសចម្រុះ
ខ.ស.ប.ប.ពគោកកម្ពុជាទី១ និង ទី២បានអនុវត្តន៍មាន :
- ឯកភាពកំណត់បានទីតាំងបង្គោលព្រំដែនចំនួន ៣១ ទីតាំង ត្រូវជា ៣៦ បង្គោលព្រំដែន
- ឯកភាពខ័ណ្ឌសីមាបានប្រវែងសរុប ១៤ ៤៤៧ គ.ម
- ដាំបង្គោលតំរុយព្រំដែនបានចំនួនសរុប ៧៤ បង្គោលតំរុយ
ព្រះរាជាណាចក្រកម្ពុជា
ខ្សែព្រំដែនគោករវាងកម្ពុជា-វៀតណាម ក្នុងកំណត់ខេត្តស្វាយរៀងមានប្រវែងប្រហែល ២៥៣.៦ គម
សាធារណរដ្ឋសង្គមនិយមវៀតណាម
16 hectar
35 hectar
128 hectar
23 hectar
14 hectar
7 hectar
51 hectar
52 hectar
62 hectar
116 hectar
61 hectar
46 hectar
442 hectar
217 hectar
31 hectar
88 hectar
Scale 1:85 000
Map Projection UTM ; Datum Indian 1960
.ផ្ទៃក្រឡាដីដែលកម្ពុជាគ្រប់គ្រងចូលខាងវៀតណាមធៀបខ្សែព្រំដែនផ្លូវការមានចំនួន ២៨៩ ហិចតា
.ផ្ទៃក្រឡាដីដែលវៀតណាមគ្រប់គ្រងចូលខាងកម្ពុជាធៀបខ្សែព្រំដែនផ្លូវការមានចំនួន ១១០០ ហិចតា


42 hectar
30.9 hectar
12.5 hectar
230-2
231-1
231-2
231-3
232-1
232-2
233-1
233-2
233-3
234
235-1
235-2
236-1
236-2
237
238
240
Scale 1:120 000
Map Projection UTM ; Datum Indian 1960


Scale 1:70 000
Map Projection UTM : Datum Indian 1960

**ព្រះករុណាព្រះបាទសម្តេច**
**ព្រះនរោត្តម សីហនុ**
**ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**

**ឯកឧត្តម ផាំ វ៉ាន់ដុង ជាទីស្រឡាញ់រាប់អានដ៏ខ្ពង់ខ្ពស់បំផុត**

ខ្ញុំមានបីតិសោមនស្សរីករាយ និងមហាកិត្តិយសប្រកបដោយមនោសញ្ចេតនានឹករឭក និងផ្ញើព្រះរាជសារលិខិតមួយនេះ ដើម្បីជម្រាបសួរសុខទុក្ខឯកឧត្តមដែលជាមហាមិត្តដ៏ឧត្តុង្គឧត្តមរបស់ខ្ញុំ ក៏ដូចជារបស់ប្រជាជនកម្ពុជាគ្រប់រូប ។

ក្នុងឱកាសដ៏កម្រនេះ ខ្ញុំសូមសម្តែងនូវមហាករុណាទិគុណដ៏ជ្រាលជ្រៅ ចំពោះមនោសញ្ចេតនាមិត្តភាពដ៏ស្មោះស្ម័គ្រ និងសាមគ្គីភាព ដែលឯកឧត្តមតែងបានផ្តល់ចំពោះរូបខ្ញុំក៏ ដូចជាចំពោះប្រជាជនកម្ពុជាក្នុងរយៈកាលកន្លងមក ដែលយើងនិងប្រជាជនយើងទាំងពីរតែងតែរួបរួមកម្លាំងគ្នាជួយគ្នាទៅវិញទៅមក ប្រកៀកស្មាគ្នាតស៊ូរំដោះប្រទេសជាតិពីសត្រូវរួម រហូតបានជោគជ័យរៀងៗខ្លួនដល់សព្វថ្ងៃនេះ។ សន្និសីទកំពូលប្រជាជនឥណ្ឌូចិននៅទីក្រុងភ្នំពេញ ថ្ងៃទី ០១ ខែ មីនា ឆ្នាំ១៩៦៥ និងទីក្រុងកង់តុង ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ១៩៧០ ការចរចារវាងខ្ញុំ និងឯកឧត្តមផ្ទាល់នៅទីក្រុងប៉េកាំងនាឆ្នាំ ១៩៦៤ និងការជួបគ្នាជាបន្តបន្ទាប់មកទៀត ក៏ដូចជាសេចក្តីថ្លែងការណ៍របស់រណសិរ្សជាតិរំដោះវៀតណាមខាងត្បូង និងសេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមដែលឯកឧត្តមជាប្រមុខ នាឆ្នាំ១៩៦៧ សុទ្ធតែបានបញ្ជាក់ពីចំណងមិត្តភាព យុទ្ធសាមគ្គីភាពព្រមទាំងការទទួលស្គាល់ព្រំដែនបច្ចុប្បន្នរបស់កម្ពុជា និងគោរពអធិបតេយ្យ បូរណភាពទឹកដី

គ្នាទៅវិញទៅមក។ រាល់ប្រសាសន៍ប្រកបដោយខ្លឹមសាររបស់ឯកឧត្តម ក្នុងឱកាសជួបប្រាស្រ័យជាមួយខ្ញុំកន្លងមកតែងតែធ្វើឱ្យខ្ញុំមានទំនុកចិត្ត និងការកក់ក្ដៅជានិច្ចចំពោះដំណោះស្រាយនានា ដែលទាក់ទងទៅនឹងផលប្រយោជន៍របស់ប្រទេសយើងទាំងពីរ ដែលជាអ្នកភូមិផងរបងជាមួយគ្នាដ៏ល្អ និងស្មោះត្រង់ ។

ឯកឧត្តមជាអ្នកធ្លាប់សិក្សាស្រាវជ្រាវយ៉ាងច្បាស់លាស់ ពីប្រវត្តិសាស្ត្រជូរចត់របស់ប្រទេសកម្ពុជាយើងខ្ញុំ ហើយឯកឧត្តមបានក្លាយទៅជាវីរជនមួយរូប ដែលបានខិតខំពង្រីកពង្រឹង មិត្តភាព យុទ្ធសាមគ្គីភាពជាមួយប្រទេសទាំងបី នៅក្នុងជ្រោយឥណ្ឌូចិនយើងនេះ តស៊ូរំដោះប្រទេសជាតិបានជោគជ័យជាស្ថាពរ ហើយកំពុងកសាងប្រទេសតាមវិទ្យាសាស្ត្របច្ចេកទេសទំនើបថ្មីដើម្បីឈានទៅរកវឌ្ឍនភាព និងសុភមង្គល ឯកឧត្តមគង់យល់ច្បាស់ អំពីភាពចាំបាច់ដែលប្រទេសយើងទាំងពីរត្រូវមានខ្សែព្រំដែនមួយសមភាពយុត្តិធម៌ និងមានផលប្រយោជន៍ទាំងសងខាង។ ជំហរនេះហើយដែលខ្ញុំសង្កេតឃើញថាអ្នកដឹកនាំរដ្ឋាភិបាលយើងទាំងពីរកំពុងយកចិត្តទុកដាក់ចរចារកដំណោះស្រាយបញ្ហាព្រំដែនដើម្បីកសាងខ្សែព្រំដែនមួយឱ្យក្លាយទៅជាខ្សែព្រំដែនសន្តិភាព សន្តិសុខ-ស្ថិរភាព-មិត្តភាព និងសហប្រតិបត្តិការ។ ឆ្លៀតឱកាសនេះដែរ ខ្ញុំក៏សូមកោតសរសើរ និងគាំទ្រដោយស្មោះចំពោះជំហរដ៏មុឹងម៉ាត់ ប្រកបដោយសុឆន្ទៈរបស់ឯកឧត្តមអគ្គលេខាធិការគណបក្សកុម្មុយ-នីស្តវៀតណាម **ឡេ ខា ភៀវ** ក្នុងឱកាសទស្សនកិច្ចនៅកម្ពុជាថ្មីៗនេះ ដែលចង់ឱ្យបញ្ហាព្រំដែននៃប្រទេសយើងទាំងពីរត្រូវបានដោះស្រាយចប់មុនដំណាច់ឆ្នាំ ២០០០ នេះ ។

ក៏ប៉ុន្តែក្នុងដំណើរការចរចានានា ដើម្បីកំណត់ព្រំដែនសមុទ្រនៃប្រទេសយើងទាំងពីរនោះ ខ្ញុំបានទទួលរបាយការណ៍ថា នៅមានការខ្វែងគំនិតគ្នានៅឡើយដែលចាំបាច់ខ្ញុំយល់ថាមានតែឯកឧត្តមដែលជាមហាមិត្តរបស់ខ្ញុំទេ ដែលលោកមានការយោគយល់បញ្ហា ហើយអាចជួយតម្រង់ទិសឱ្យគណៈកម្មការចម្រុះកិច្ចការព្រំដែនប្រទេសយើងទាំងពីរ មានពន្លឺក្នុង

ការស្វែងរកដំណោះស្រាយមួយសមហេតុសមផល ស្របតាមផលប្រយោជន៍របស់ប្រជាជនយើងទាំងពីរ ។

ឯកឧត្តម ជាទីរាប់អានដ៏ខ្ពង់ខ្ពស់បំផុត

ក្នុងប្រវត្តិសាស្ត្រកម្ពុជា ទឹកដីកម្ពុជាក្រោមទាំងមូលបានបាត់បង់រួចទៅហើយ បន្ទាប់មកកោះត្រល់ដែលវៀតណាមឱ្យឈ្មោះថា ហ្វ៊ូ កុក និងកោះមួយចំនួនដែលស្ថិតនៅខាងត្បូងខ្សែបន្ទាត់ ប្រេវីយេ ក៏បន្តបាត់ទៀតដោយសារសារាចររបស់លោកអគ្គទេសាភិបាលបារាំងថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៣៩ ។ ម្យ៉ាងវិញទៀត កាលពីឆ្នាំ ១៩៦៤ រាជរដ្ឋាភិបាលកម្ពុជាពេលនោះ បានយកផែនទីមួយដែលបោះពុម្ពដោយក្រុមភូមិសាស្ត្រកម្ពុជា ផ្អែកតាមផែនទីបារាំងរបស់ Service Hydrographique ខ្នាត ១/៣០០.០០០ ភ្ជាប់ជាមួយផែនទីដីគោកទៅឱ្យអន្តរជាតិទទួលស្គាល់ និងបានតម្កល់ទុកនៅអង្គការសហប្រជាជាតិនោះ គឺយើងបានគូសខ្សែប្រេវីយេ ជាព្រំដែនសមុទ្រជាមួយវៀតណាមផងដែរ ។ផែនទី និងឯកសារទាំងអស់នោះហើយ ដែលអតីតរាជរដ្ឋាភិបាលរបស់ខ្ញុំ អតីតរាជរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា រដ្ឋកម្ពុជា និងរាជរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្ន កំណត់ថាជាព្រំដែនបច្ចុប្បន្នរបស់កម្ពុជា។ ដូច្នេះហើយ ខ្ញុំយល់ឃើញថា សម័យកាលបច្ចុប្បន្ននេះ ដែលសកលលោកទាំងមូលកំពុង ស្វែងរកការសម្របសម្រួលអំពីព្រំដែន យើងគួរយកខ្សែប្រេវីយេនេះ ដើម្បីខណ្ឌព្រំសីមា ដែនសមុទ្ររបស់ប្រទេសយើងទាំងពីរ ដើម្បីទុកឱ្យកូនចៅយើងជំនាន់ក្រោយទទួលបាននូវមរតកមួយដ៏ច្បាស់លាស់សម្រាប់ការគ្រប់គ្រង និងអភិវឌ្ឍន៍ប្រទេសរៀងៗខ្លួន ។

ជាទីបញ្ចប់ ខ្ញុំសូមសម្តែងនូវក្តីសង្ឃឹមជឿជាក់ថា ប្រទេសយើងទាំងពីរនឹងបន្តអនុវត្តគំរូវីរភាពរបស់យុទ្ធជន យុទ្ធនារីយើង ដើម្បីរក្សាមិត្តភាព សាមគ្គីភាព សហប្រតិបត្តិការដ៏យូរលង់រវាងប្រជាជន និងប្រជាជាតិយើងទាំងពីរ ខិតខំកសាងខ្សែព្រំដែនគោក

និងសមុទ្រឱ្យបានទៅជាខ្សែព្រំដែនមួយសន្តិភាព សន្តិសុខ ស្ថិរភាព មិត្តភាព និងសហប្រតិបត្តិការឱ្យបានមុនឆ្នាំ ២០០០ ស្របតាមបំណងប្រាថ្នារបស់ប្រជាជនយើងទាំងពីរ ។

សូមឯកឧត្តមទទួលនូវការនឹករលឹក និងការរាប់អានប្រកបដោយមនោសញ្ចេតនាជាភាគរះដ៏ខ្ពង់ខ្ពស់បំផុតពីខ្ញុំ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ១៩៩៩

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

រូបភាព បង្គោលព្រំដែនប្រភេទ A បោះនៅច្រកទ្វារអន្តរជាតិ (ឈក-កំពត)



រូបភាព  បង្គោលព្រំដែនប្រភេទ  B  បោះនៅច្រកទ្វេភាគី  (កំពង់ចាម)



រូបភាព បង្គោលព្រំដែនប្រភេទ C បោះនៅច្រកតំបន់ និង នៅតំបន់លិចទឹក



## បង្គោលព្រំដែនលេខ សូន្យ (O) នៅព្រំដែន ៣ ប្រទេសកម្ពុជា-ឡាវ-វៀតណាម



ចងក្រងដោយ

ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ និង លេខាធិការដ្ឋាន
អចិន្ត្រៃយ៍នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន
សីហា ២០១២